គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ

ឥណទានពលរដ្ឋរុងរឿង អិលធីឌី

INTEAN POALROATH RONGROEURNG LTD



# របាយការណ៍ប្រចាំឆ្នាំ

# 2021

# តារាងមាតិកា


| | |
|---|---|
| មាតិកា | 2 |
| ទស្សនវិស័យ បេសកកម្ម និងតម្លៃស្នូល | 3 |
| ប្រវត្តិគ្រឹះស្ថាន | 4 |
| សាររបស់ប្រធានក្រុមប្រឹក្សាភិបាល | 5 |
| ក្រុមប្រឹក្សាភិបាល | 6 |
| សាររបស់នាយិកាប្រតិបត្តិ | 7 |
| គណៈគ្រប់គ្រងក្រុមហ៊ុន | 8 |
| ភាគទុនិក និងវិនិយោគិន | 10 |
| អង្គការលេខ | 12 |
| រចនាសម្ព័ន្ធសាខា | 13 |
| អតិថិជនគោលដៅ និងផលិតផល | 14 |
| លទ្ធផលការងារឆ្នាំ 2021 | 15 |
| ទិន្នន័យសំខាន់ៗ | 16 |
| លទ្ធផលការងារ | 17 |
| បទពិសោធន៍របស់អតិថិជន | 20 |
| សវនកម្មផ្ទៃក្នុង និងការត្រួតពិនិត្យ | 22 |
| បុគ្គលិក និងការកសាងសមត្ថភាព | 23 |
| ទំនួលខុសត្រូវរបស់ ឥណទានពលរដ្ឋរុងរឿង | 24 |
| របាយការណ៍បង់ពន្ធ | 25 |
| សម្រង់របាយការណ៍សវនកម្មហិរញ្ញវត្ថុឆ្នាំ 2021 | 26 |
| របាយការណ៍របស់ក្រុមប្រឹក្សាភិបាល | 27 |
| របាយការណ៍របស់សវនករឯករាជ្យ | 31 |
| របាយការណ៍ស្ថានភាពហិរញ្ញវត្ថុ | 34 |
| របាយការណ៍លទ្ធផលលម្អិត | 35 |
| របាយការណ៍ស្តីពីបម្រែបម្រួលមូលធន | 36 |
| របាយការណ៍លំហូរទឹកប្រាក់ | 37 |
| ព័ត៌មានទំនាក់ទំនង | 38 |
| បណ្តាញសាខា | 39 |


2
0
2
1

# ទស្សនវិស័យ
# បេសកកម្ម និងតម្លៃស្នូល

## ទស្សនវិស័យ

ជាគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ កម្ពុជា
បម្រើវិស័យកសិកម្មឈានមុខគេ។

## បេសកកម្ម

ផ្តល់នូវសេវាហិរញ្ញវត្ថុ ងាយស្រួល
ស្របទៅតាមអាជីវកម្មដែល
ពាក់ព័ន្ធនឹង កសិកម្ម ដើម្បី
ធ្វើឲ្យប្រសើរឡើងនូវលក្ខខណ្ឌ
សេដ្ឋកិច្ចរបស់កសិករ ដោយធានា
បាននូវការរីកចម្រើនដោយមាននិរន្តភាព
របស់គ្រឹះស្ថាន។

## គុណតម្លៃ

. ស្មោះត្រង់ និងសុច្ចរិត
. ទទួលខុសត្រូវខ្ពស់
. ការបំពេញការងារជាក្រុម
. តម្លាភាព

# ប្រវត្តិគ្រឹះស្ថាន

### ឆ្នាំ ២០២០

គ្រឹះស្ថានបានរងផលប៉ះពាល់ពីការឆ្លងរីករាលដាលនៃជម្ងឺ កូវីដ ១៩ ដែលទាមទាអោយមានការប្រឹងប្រែងអត់ធ្មត់ និងពេលវេលាដើម្បីស្តារស្ថានភាពអោយប្រសើរឡើងវិញ។

### ឆ្នាំ ២០១៧

គ្រឹះស្ថានបានរងផលប៉ះពាល់ពីការថយចុះនៃផលបត្រឥណទាន ដែលជះឥទ្ធិពលពីការកំហិតពិដានការប្រាក់របស់ ធនាគារជាតិនៃកម្ពុជា។

### ឆ្នាំ ២០១៥

Leopard Cambodia Fund បានចាកចេញពីភាគទុនិកតាមរយៈការលក់ភាគហ៊ុនទាំងមូលរបស់ខ្លួនឲ្យលោកឧកញ៉ា ភួ ពុយ។

### ឆ្នាំ ២០១១

គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុឥណទានពលរដ្ឋរុងរឿង មានភាពល្អប្រសើរឡើងវិញពីវិបត្តិផលបត្រ ឥណទាន ជាមួយការពង្រឹងដំណើរការផ្ទៃក្នុង ការបន្តអភិវឌ្ឍន៍ និងវិវត្តន៍ខ្លួនជាគ្រឹះស្ថានមួយដែលទទួលបានប្រាក់ចំណេញច្រើន ក្នុងចំណោមគ្រឹះស្ថានផ្សេងៗទៀត។

### ឆ្នាំ ២០១០

លោកស្រី ហៅ ស៊ីមន បានចាកចេញពីភាគទុនិក ហើយ Leopard Cambodia Fund បានក្លាយជាភាគទុនិកភាគតិចតាមរយៈក្រុមហ៊ុន IPR ( KH ) ដែលមានមូលដ្ឋាននៅហុងកុង។

### ឆ្នាំ ២០០៩ -១០

គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុឥណទានពលរដ្ឋរុងរឿង ទទួលរងផលប៉ះពាល់ពីវិបត្តិហិរញ្ញវត្ថុសកលលោក និងបញ្ហាប្រឈមផ្ទៃក្នុង។

### ឆ្នាំ ២០០៨

ឥណទានពលរដ្ឋរុងរឿង ទទួលបានអាជ្ញាប័ណ្ណអចិន្ត្រៃយ៍ជាគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុពីធនាគារជាតិនៃកម្ពុជា។

### ឆ្នាំ ២០០៣

គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុឥណទានពលរដ្ឋរុងរឿង បង្កើតឡើងក្នុងនាមជាផ្នែកឥណទាននៃសម្ព័ន្ធសមាគមម៉ាស៊ីនកិនស្រូវកម្ពុជា។

# សាររបស់
# ប្រធានក្រុមប្រឹក្សាភិបាល



**លោកឧកញ៉ា ត្ន ពុយ**

**ប្រធានក្រុមប្រឹក្សាភិបាល**

ឆ្នាំ 2021 គឺជាឆ្នាំដ៏លំបាកមួយសម្រាប់អាយភីអា ដោយសារតែវិបត្តិ កូវីដ១៩ ទោះជាយ៉ាងណាក៏ដោយស្ថាប័ននេះអាចទប់ទល់នឹងផលប៉ះពាល់ ដោយឆ្លើយតបយ៉ាងឆាប់រហ័សទៅតាមស្ថានភាព នឹងធានាថាបុគ្គលិក និងអតិថិជនរបស់ខ្លួនបានទទួលនូវជំនួយដែលពួកគេត្រូវការ។ នៅដើមឆ្នាំ 2021 នៅពេលដែលមានការផ្ទុះឡើងនៃការឆ្លងជាសហគមន៍ អាយភីអាបានឆ្លើយតបបានយ៉ាងឆាប់រហ័ស ដោយសារកិច្ចសហប្រតិបត្តិការជិតស្និទ្ធរវាងគណៈគ្រប់គ្រង និងក្រុមប្រឹក្សាភិបាល។ យើងបានព្យាយាមធ្វើយ៉ាងណាធានាបាននូវសុវត្ថិភាពរបស់និយោជិត និងអតិថិជនរបស់យើងជាមុន ដោយការបង្កើនការយល់ដឹងអំពីវិធានការការពារ និងការអនុញ្ញាតឲ្យបុគ្គលិកធ្វើការពីផ្ទះតាមដែលអាចធ្វើទៅបាន។

សូមអរគុណដល់ការបន្តគាំទ្រពីធនាគារជាតិនៃកម្ពុជា ដែលអនុញ្ញាតឱ្យស្ថាប័ននានាអាចរៀបចំឥណទានឡើងវិញជូនអតិថិជនដែលជួបប្រទះភាពលំបាកផ្នែកហិរញ្ញវត្ថុដោយសារជំងឺរាតត្បាតកូវីដ១៩នេះ។ ដើម្បីកាត់បន្ថយផលវិបាករបស់ពួកគេក្នុងការទូទាត់សងត្រឡប់ អាយភីអា បានផ្តល់ឲ្យពួកគេនូវភាពបត់បែនបន្ថែមសម្រាប់លក្ខខណ្ឌនៃការសង ដោយស្របតាមគោលការណ៍រៀបចំឥណទានឡើងវិញ ដោយមានការពន្យាឥណប្រតិទានរបស់កម្ចី និងពន្យាការសងចូលប្រាក់ដើមជូនដល់អតិថិជនដែលកំពុងជួបផលវិបាកក្នុងកំឡុងពេលនេះ។

ទន្ទឹមនឹងនេះ អាយភីអា ក៏បានអនុវត្តការប្រុងប្រយ័ត្នក្នុងការបញ្ចេញកម្ចី និងពន្យឺតផែនការកំណើនផលប័ត្រឥណទានផងដែរ ដើម្បីកាត់បន្ថយហានិភ័យសម្រាប់អតិថិជន និងសម្រាប់ក្រុមហ៊ុន។ ជាក់ស្តែងលទ្ធផលរបស់ អាយភីអា បានធ្លាក់ចុះនៅក្នុងឆ្នាំ 2021 យ៉ាងណាមិញយើងនៅតែរក្សាបាននូវគោលជំហររឹងមាំ និងធានាបាននូវភាពរឹងមាំនៃសាច់ប្រាក់របស់ក្រុមហ៊ុនក្នុងកំឡុងពេលដ៏ពិបាកនេះ។

អាយភីអា នៅតែបន្តបេសកកម្មរបស់ខ្លួននៅក្នុង វិស័យកសិកម្ម ដែលនៅតែជាឆ្អឹងខ្នងនៃសេដ្ឋកិច្ចរបស់ប្រទេសកម្ពុជា។ ដូច្នេះ វិស័យកសិកម្មនៅតែជាចំណែកទីផ្សារដ៏សំខាន់របស់អាយភីអា ក្នុងពេលបច្ចុប្បន្ន និងនាពេលអនាគត។

ជាពិសេស យើងបានបង្កើតគំរូអាជីវកម្មកាន់តែទូលំទូលាយតាមខ្សែសង្វាក់ផលិតកម្មកសិកម្ម តាមរយៈដៃគូសហការបន្ថែម។ ការរួមបញ្ចូលគ្នានៃផលចំណេញ អនុបាតបំណុលទាប ការផ្តោតលើកសិកម្ម និងឥទ្ធិពលសង្គមបែបវិជ្ជមានទៅលើកសិករជនបទ ធ្វើឱ្យយើងមានភាពទាក់ទាញសម្រាប់ការវិនិយោគ។ បូករួមទាំងការកើនឡើងនៃជម្រើសផលិតផលដែលអាយភីអាផ្តល់ជូន យើងសង្ឃឹមថា អាយភីអានឹងអាចឈានដល់ការទទួលបានកំណើនមូលដ្ឋានអតិថិជនច្រើន ដែលស្របទៅតាមស្ថានភាពសេដ្ឋកិច្ចបច្ចុប្បន្ន។

អាយភីអា នៅតែជាគ្រឹះស្ថានដ៏រឹងមាំមួយ បើគិតពីមូលធនភាគទុនិក និងជំហរយុទ្ធសាស្ត្រទីផ្សារច្បាស់លាស់។ អាយភីអា នឹងព្យាយាមដើម្បីទទួលបានការរីកចម្រើន និងរក្សាសុខភាពហិរញ្ញវត្ថុរបស់ខ្លួនអោយបានរឹងមាំនឹងយូរអង្វែង។

ខ្ញុំសូមថ្លែងអំណរគុណ និងកោតសរសើរខ្ពស់ចំពោះសមាជិកក្រុមប្រឹក្សាភិបាល ដៃគូរសហការរបស់យើង អតិថិជនដ៏មានតម្លៃ គណៈគ្រប់គ្រង គ្រឹះស្ថាន និងបុគ្គលិកគ្រប់ជាន់ថ្នាក់ ចំពោះការប្តេជ្ញាចិត្ត និងឆន្ទៈដ៏មុតមាំរបស់អ្នកទាំងអស់គ្នា។

ដោយការគោរពស្មោះស្ម័គ្រអំពីខ្ញុំ

ឧកញ៉ា ត្ន ពុយ

ប្រធានក្រុមប្រឹក្សាភិបាល

# ក្រុមប្រឹក្សាភិបាល



## លោកឧកញ៉ា ភួ ពុយ

### ប្រធានក្រុមប្រឹក្សាភិបាល

**លោកឧកញ៉ា ភួ ពុយ** ជាស្ថាបនិក និងជាប្រធានក្រុមប្រឹក្សាភិបាលនៃគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុឥណទានពលរដ្ឋរុងរឿង ចាប់តាំងពីការចាប់ផ្តើមដំបូងនៃការកកើតគ្រឹះស្ថាន។ លោកឧកញ៉ាជាសហគ្រិនកសិកម្មឈានមុខគេម្នាក់ ជាពិសេសនៅក្នុងវិស័យម៉ាស៊ីនកិនស្រូវ ជាប្រធាន និងជានាយកប្រតិបត្តិក្រុមហ៊ុនបៃតងកម្ពុជា ភីអិលស៊ី ដែលជាក្រុមហ៊ុនម៉ាស៊ីនកិនស្រូវធំជាងគេបង្អស់នៅកម្ពុជា។



## លោក ហ្សូ មីងយី

### អភិបាលឯករាជ្យ

**លោក ហ្សូ មីងយី** ជាសមាជិកក្រុមប្រិក្សាភិបាលរបស់ IPR ចាប់តាំងពីឆ្នាំ២០១៥ និងបានក្លាយជាប្រធានគណៈកម្មការសវនកម្ម និងហានិភ័យចាប់តាំងពីឆ្នាំ២០១៩។ បច្ចុប្បន្នលោកជាទីប្រឹក្សាឯករាជ្យលើមីក្រូហិរញ្ញវត្ថុ និងជាវិនិយោគិនមួយរូបផងដែរ។ លោកធ្លាប់បំរើការងារក្នុងគ្រឹះស្ថានឥណទានពលរដ្ឋរុងរឿង ជាទីប្រឹក្សា និងជានាយកប្រតិបត្តិការ។ លោកក៏ធ្លាប់បំរើការងារនៅ ADA ដែលនៅទីនោះ លោកបានចូលរួមក្នុងការសម្របសម្រួលបង្កើតមីក្រូហិរញ្ញវត្ថុលុចហ្សំបួរ និងមូលនិធិអភិវឌ្ឍន៍ និងជាអ្នកគ្រប់គ្រងផលប័ត្រវិនិយោគនៅក្នុងតំបន់អាស៊ី និងអាហ្វ្រិកខាងកើត។ លោកក៏មានបទពិសោធន៍ធ្វើការជាមួយគណកម្មការអឺរ៉ុបជាមន្ត្រីសេដ្ឋកិច្ច និងពាណិជ្ជកម្មនៅក្នុងប្រទេសម៉ាឡេស៊ី។ បន្ថែមពីលើនេះទៀត លោកមានបទពិសោធន៍ធ្វើការនៅក្នុងផ្នែកស្ថេរភាពហិរញ្ញវត្ថុ នៅក្នុងធនាគារកណ្តាលរបស់លុចហ្សំបួរផងដែរ។



## លោកស្រី ប៉ុក នីរិល័យ

### អភិបាលឯករាជ្យ

**លោកស្រី ប៉ុក នីរិល័យ** ត្រូវបានតែងតាំងជាសមាជិកក្រុមប្រឹក្សាភិបាលឯករាជ្យតាំងពីខែមេសា ឆ្នាំ២០១៦។ លោកស្រីមានបទពិសោធន៍ការងារជាច្រើនឆ្នាំលើផ្នែកលក់ និងទីផ្សារ ផ្នែកទំនាក់ទំនង និងគណនេយ្យ។ លោកស្រីធ្លាប់បានបំពេញការងារជានាយកទីផ្សារនិងទំនាក់ទំនង ជាប្រធានគណនេយ្យ ជាប្រធានគ្រប់គ្រងផ្នែកលក់ និងជាអ្នកសម្របសម្រួលនៅក្នុងកម្មវិធីទូរទស្សន៍ផងដែរ។ លោកស្រី នីរិល័យ បានបញ្ចប់ថ្នាក់អនុបណ្ឌិត និងបរិញ្ញាប័ត្រផ្នែក គ្រប់គ្រងអាជីវកម្ម លើជំនាញគ្រប់គ្រងអាជីវកម្មទូទៅ។



## លោក ប៊ិច សានី

### អភិបាលឯករាជ្យ

**លោក ប៊ិច សានី** បានតែងតាំងជាសមាជិកក្រុមប្រឹក្សាភិបាលឯករាជ្យ ក្នុងខែមករាឆ្នាំ២០២០។ លោកមានតំណែងជាអគ្គនាយករងទទួលបន្ទុកនាយកដ្ឋានប្រតិបត្តិការ និងកិច្ចការរតនាគារ និងនាយកដ្ឋានគណនេយ្យ និងហិរញ្ញវត្ថុ នៃធនាគារអភិវឌ្ឍន៍ជនបទ និងកសិកម្ម (ARDB)។ លោក ប៊ិច សានី មានបទពិសោធន៍ការងារក្នុងវិស័យធនាគារជាង២០ឆ្នាំមកហើយ។ មុននឹងចូលបម្រើការងារនៅធនាគារអភិវឌ្ឍន៍ជនបទ និងកសិកម្ម ក្នុងឆ្នាំ២០០១ លោកបានបម្រើការងារ និងមានបទពិសោធន៍ការងារជាច្រើននៅធនាគារជាតិនៃកម្ពុជា និងនៅធនាគារពាណិជ្ជ។ លោក បានបញ្ចប់ថ្នាក់បរិញ្ញាប័ត្រផ្នែកធនាគារ ពីសកលវិទ្យាល័យធនាគារក្នុងប្រទេសវៀតណាម និងបានបញ្ចប់ថ្នាក់អនុបណ្ឌិតផ្នែកហិរញ្ញវត្ថុ ពីសកលវិទ្យាល័យជាតិគ្រប់គ្រងក្នុងឆ្នាំ២០០៤។

# សាររបស់
# នាយកប្រតិបត្តិ



**តួ សុវណ្ណាច័ន្ទ**
**នាយិកាប្រតិបត្តិ**

ឆ្នាំ 2021 គឺជាឆ្នាំដ៏លំបាកសម្រាប់ អាយភីអា និងសហគមន៍ទាំងមូល។ ក្នុងកំឡុងដើមឆ្នាំ ដែលមានការផ្ទុះឡើងនៃការឆ្លងជាសហគមន៍នៃ ជំងឺកូវីដ១៩ យើងបានប្រតិកម្មយ៉ាងឆាប់រហ័ស ដោយការស្វែងរកដំណោះស្រាយ ដើម្បីជួយអតិថិជនរបស់យើងដែលរងផលប៉ះពាល់ដោយ ជំងឺរាតត្បាតនេះ។ យើងបានអនុវត្តផែនការបន្តអាជីវកម្មរបស់យើង (BCP) ក្រោមការដឹកនាំ របស់គណៈកម្មាធិការ BCP ដោយដាក់ចេញនូវនីតិវិធី សកម្មភាព និងការណែនាំដែលត្រូវ អនុវត្តតាម ដើម្បីធានាថាយើងអាចរក្សាអតិថិជន និងនិយោជិតរបស់យើងឲ្យមានសុវត្ថិភាព ទន្ទឹមនឹងនោះក៏ធានាបាននូវការបន្តអាជីវកម្មរបស់យើងផងដែរ។

ដូចគ្នានេះដែរ អាទិភាពទីមួយរបស់យើងក្នុងអំឡុងពេលនេះគឺធានាបាននូវសុវត្ថិភាពរបស់ អតិថិជន និងបុគ្គលិករបស់យើង។ ទោះបីជាមានស្ថានភាពលំបាកយ៉ាងណាក៏ដោយ ពួកយើង អាចឈរជើងបានយ៉ាងរឹងមាំ អរគុណចំពោះការណែនាំរបស់ក្រុមប្រឹក្សាភិបាល និងកិច្ចសហ ប្រតិបត្តិការយ៉ាងជិតស្និទ្ធរវាងគណៈគ្រប់គ្រង។

ដូចស្ថាប័នជាច្រើននៅក្នុងវិស័យនេះ លទ្ធផលហិរញ្ញវត្ថុរបស់យើងត្រូវបានរងផលប៉ះពាល់ដោយសារបញ្ហាកូវីដ១៩ ជាពិសេសការបន្តឆ្លងករណី ថ្មីៗក្នុងសហគមន៍ ដែលបានកើតឡើងដោយមិនបាននឹកស្មាន។ ចាប់តាំងពីឆ្នាំ 2020 នៅពេលដែលជំងឺកូវីដ១៩បានវាយប្រហារជាលើកដំបូង រហូតដល់ឆ្នាំ 2021 នេះ អាយភីអា បានរឹតបន្តឹងកំណើននៃការបញ្ចេញកម្ចី ដើម្បីការពារនូវហានិភ័យ និងធានាបាននូវនិរន្តរភាពរបស់ក្រុមហ៊ុន ជាពិសេសក្នុងអំឡុងពេលដែលពិបាកសន្ទុះនេះ។ ជាលទ្ធផល ផលប័ត្រឥណទានសរុបរបស់អាយភីអា បានកើនឡើងត្រឹមតែ 4.6% ដែល ផលប័ត្រប្រាក់កម្ចីឈានដល់ 6.8 លានដុល្លារអាមេរិក ហើយយើងអាចរក្សាបាននូវគុណភាពផលប័ត្រឥណទានដែលអាចទទួលយកបាន ជាមួយ NPL 2.05% ថយចុះពីឆ្នាំកន្លងទៅ(2.29%) និងប្រសើរជាងវិស័យ MFI ទាំងមូលដែលមានមធ្យមភាគ 2.4% នៃ NPL ។ យើងក៏បាន ព្យាយាមកាត់បន្ថយប្រាក់កម្ចីដែលបានលុបចេញពីបញ្ជីអោយមកនៅត្រឹម 1.47% ក្នុងឆ្នាំនេះ។

ចាប់តាំងពីឆ្នាំមុននៅពេលដែល អាយភីអា បានសម្របខ្លួនជាមួយបរិយាកាសទីផ្សារតាមរយៈការកែប្រែផលិតផលឥណទានដែលមានស្រាប់ និង ការរចនាផលិតផលថ្មីដើម្បីឆ្លើយតបទៅនឹងការផ្លាស់ប្តូរអាកប្បកិរិយារបស់អតិថិជន យើងបានឃើញលទ្ធផលវិជ្ជមាន ហើយទោះបីជាលទ្ធផល នៅឆ្នាំ2021 នេះបានធ្លាក់ចុះក៏ដោយ អាយភីអា នឹងបន្តរក្សាភាពបត់បែនទៅតាមឥរិយាបទទីផ្សារ តាមរយៈការធ្វើពិពិធកម្មនៃផលិតផលកម្ចីថ្មី ដើម្បីបំពេញតម្រូវការរបស់អតិថិជនដែលមានស្រាប់ និងអតិថិជនថ្មីរបស់យើង។

សូមអរគុណចំពោះការគាំទ្រជាបន្តបន្ទាប់ និងការត្រួតពិនិត្យយ៉ាងប្រុងប្រយ័ត្នរបស់ធនាគារជាតិនៃកម្ពុជា និងដើម្បីឆ្លើយតបទៅនឹងការណែនាំ របស់ធនាគារជាតិនៃកម្ពុជា យើងបានរៀបចំឥណទានឡើងវិញជូនដល់អតិថិជនដែលរងគ្រោះដោយសារជំងឺរាតត្បាតកូវីដ១៩ ដើម្បីជួយកាត់បន្ថយ បន្ទុកសងត្រលប់របស់ពួកគាត់។ នៅឆ្នាំ 2021 យើងបានរៀបចំឥណទានឡើងវិញជូនអតិថិជនចំនួន 142 នាក់ ដែលមានសមតុល្យឥណទាន ស្មើនឹង USD 637,656 ។

ដើម្បីឆ្លើយតបទៅនឹងការផ្លាស់ប្តូរបរិយាកាសទីផ្សារ ជាពិសេសនៅក្នុងយុគសម័យនៃការប្រែប្រួលអាកាសធាតុ អាយភីអា នឹងបន្តសម្របខ្លួន និង ធ្វើឱ្យមានភាពប្រសើរឡើង។ អាយភីអាក៏នឹងបន្តផ្តោតលើការពង្រឹង និងការកែលម្អដំណើរការផ្ទៃក្នុង និងយុទ្ធសាស្រ្តអាជីវកម្មរបស់ខ្លួនដើម្បី សម្រេចបាននូវផលិតភាព និងនិរន្តរភាពកាន់តែប្រសើរឡើង ព្រមជាមួយការគិតគូរពីកត្តាអាកាសធាតុផងដែរ។ ជាចំណុចបន្ថែម ដំណើរការ នៃប្រតិបត្តិការដែលប្រើប្រាស់ដោយប្រព័ន្ធបច្ចេកវិទ្យា គឺបន្តជាកត្តាសំខាន់មួយដែលអាយភីអា ត្រូវការនិងបន្តសម្រេចនាថ្ងៃមុខ។ ស្របពេល ជាមួយគ្នានេះ ដើម្បីបង្ហាញពីការប្តេជ្ញាចិត្តរបស់យើងចំពោះអតិថិជន អាយភីអា ប្តេជ្ញានឹងព្យាយាមអោយទទួលបានវិញ្ញាបនបត្រគោលការណ៍ការពារ អតិថិជន(CPP)នៅក្នុងប៉ុន្មានឆ្នាំខាងមុខនេះ។

ក្នុងនាមគណៈគ្រប់គ្រងក្រុមហ៊ុន ខ្ញុំសូមថ្លែងអំណរគុណយ៉ាងស្មោះអស់ពីចិត្តចំពោះបុគ្គលិកគ្រប់ជាន់ថ្នាក់ ក្រុមប្រឹក្សាភិបាល ម្ចាស់ភាគហ៊ុន និង វិនិយោគិនទាំងអស់ ចំពោះការគាំទ្រ និងការណែនាំនាពេលកន្លងមក។ យើងនឹងបន្តកិច្ចការខិតខំប្រឹងប្រែង និងការសហការដើម្បីលើកកម្ពស់ គ្រឹះស្ថានឲ្យបន្តរីកចម្រើនទៅមុខជាលំដាប់។ ជាពិសេសការឆ្លុះបញ្ចាំងនិងយល់ដឹងអំពីស្ថាប័ន និងបន្តការកែលម្អគឺជាកត្តាចាំបាច់។

**តួ សុវណ្ណាច័ន្ទ**
**នាយិកាប្រតិបត្តិ**

# គណៈគ្រប់គ្រងក្រុមហ៊ុន



## កញ្ញា ភួ សុវណ្ណច័ន្ទ
### នាយិកាប្រតិបត្តិ
**( តែងតាំងនៅថ្ងៃទី ០១ មករា ឆ្នាំ ២០២១ )**

**កញ្ញា ភួ សុវណ្ណច័ន្ទ** ត្រូវបានតែងតាំងជានាយិកាប្រតិបត្តិនៅថ្ងៃទី ០១ ខែមករា ឆ្នាំ ២០២១។ គាត់ធ្លាប់បានបំពេញតួនាទីជា មន្ត្រីប្រតិបត្តិតាម នៅក្នុងគ្រឹះស្ថាន ចាប់តាំងពីខែកក្កដា ឆ្នាំ ២០១៩។ ពីមុនមក គាត់បានបំពេញការងារជាជំនួយការនាយកប្រតិបត្តិ ហាត់ការរយៈពេល ៦ ខែក្នុងឆ្នាំ ២០១៨។

សុវណ្ណច័ន្ទ បានទទួលសញ្ញាបត្របរិញ្ញាបត្រគ្រប់គ្រងធុរកិច្ច ជំនាញគណនេយ្យ និងហិរញ្ញវត្ថុពីCamEd Business School, ហើយក្នុងអំឡុងពេលជាមួយគ្នានោះ កញ្ញាទទួលបានសញ្ញាបត្រ Certified Accounting Technician（CAT）ផងដែរ។ ក្រោយមក នៅឆ្នាំ២០២០ គាត់បានបញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រងពាណិជ្ជកម្មអន្តរជាតិ ពីសកលវិទ្យាល័យ Grenoble École de Management នៅប្រទេសសឹង្ហបូរី  និង អំឡុងពេលសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ឆ្នាំទី ២ គាត់បានចាប់ផ្តើមការងារជាមួយគ្រឹះស្ថានជា មន្ត្រីប្រតិបត្តិតាម ដែលជាពេលដែលគាត់បានទទួលវិញ្ញាបនបត្រ Regulatory Compliance Certificate ពីវិទ្យាស្ថានធនាគារនិងហិរញ្ញវត្ថុ ដែលជាកម្មសិទ្ធិរបស់សមាគមធនាគារកម្ពុជា។ បច្ចុប្បន្ន សុវណ្ណច័ន្ទកំពុងបន្តការសិក្សាជំនាញ Charter Banker ដែលផ្តល់ជូនដោយ Charter Banker Institute, ពីចក្រភពអង់គ្លេស។



## លោក ចេង វណ្ណេត
### នាយកប្រតិបត្តិការ

**លោក ចេង វណ្ណេត** បំពេញតួនាទីជានាយកប្រតិបត្តិការតាំងពីខែកញ្ញា ឆ្នាំ ២០១៩។ លោកចាប់ផ្តើមការងារដំបូង នៅក្នុងគ្រឹះស្ថាន ក្នុងខែមករា ឆ្នាំ ២០១០ និងបានបម្រើការងារក្នុងមុខតំណែងជាច្រើន ដូចជា ប្រធានផ្នែកស្តារបំណុល ប្រធានសាខាមេ ប្រធានផ្នែកឥណទាន នាយកប្រតិបត្តិការស្តីទី និង នាយកសវនកម្មផ្ទៃក្នុងផងដែរ។ មុនបំរើការងារនៅទីនេះ លោកធ្លាប់បំរើការងារក្នុងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុផ្សេងក្នុងតួនាទីជាមន្ត្រីឥណទាន និងប្រធានផ្នែកប្រតិបត្តិការ។

លោក វណ្ណេត បានទទួលបរិញ្ញាបត្រជាន់ខ្ពស់ផ្នែកធុរកិច្ច និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ជំនាញគ្រប់គ្រងពីសកលវិទ្យាល័យបញ្ញាជាតិ ក្នុងឆ្នាំ២០១៤ និង បរិញ្ញាបត្រវិទ្យាសាស្ត្រសេដ្ឋកិច្ច ជំនាញអភិវឌ្ឍន៍សេដ្ឋកិច្ចជនបទពីសកលវិទ្យាល័យភូមិន្ទនិតិសាស្ត្រ និងសេដ្ឋកិច្ច។ ក្រៅពីនេះ លោកបានចូលរួមវគ្គបណ្តុះបណ្តាលជាច្រើនទាក់ទងនឹងការគ្រប់គ្រងក្នុងវិស័យមីក្រូហិរញ្ញវត្ថុ។

# គណៈគ្រប់គ្រងក្រុមហ៊ុន



## លោក ហៃ គឹមឃន
### នាយកហិរញ្ញវត្ថុ និងរដ្ឋបាល

**លោក ហៃ គឹមឃន** ជានាយកហិរញ្ញវត្ថុតាំងពីឆ្នាំ ២០០៩។ លោកបានបំពេញការងារជាមួយគ្រឹះស្ថានមានរយៈពេលច្រើនជាង ១៥ ឆ្នាំ ចាប់តាំងពីឆ្នាំ ២០០៦ ក្នុងមុខតំណែងផ្សេងៗគ្នាជាច្រើនដូចជា ជំនួយការប្រធានសាខា ប្រធានសាខា និងនាយកប្រតិបត្តិការ។ មុនចូលបំពេញការងារនៅទីនេះ លោកជាអ្នកកាន់បញ្ជីគណនេយ្យក្នុងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមួយ។

លោក គឹមឃន បានទទួលបរិញ្ញាប័ត្រផ្នែកគ្រប់គ្រងធុរកិច្ច ជំនាញហិរញ្ញវត្ថុ និងគណនេយ្យ និងបរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងធុរកិច្ច ជំនាញគ្រប់គ្រង ពីសាកលវិទ្យាល័យគ្រប់គ្រង និងសេដ្ឋកិច្ច ខេត្តបាត់ដំបង។ ក្រៅពីនេះ លោកបានចូលរួមវគ្គបណ្តុះបណ្តាលជាច្រើនទាក់ទងនឹងការគ្រប់គ្រងក្នុងវិស័យមីក្រូហិរញ្ញវត្ថុ។



## លោក គៀក កោវិទ្ធ
### នាយកព័ត៌មានវិទ្យាស្តីទី

**លោក គៀក កោវិទ្ធ** បានតែងតាំងជាប្រធានបច្ចេកវិទ្យាព័ត៌មាន ក្នុងខែកុម្ភៈ ឆ្នាំ២០២០។ លោកធ្លាប់ជាប្រធានបច្ចេកវិទ្យាព័ត៌មាន នៅក្រុមហ៊ុនលីហួរប្តូរប្រាក់ ក្នុងឆ្នាំ២០១៨ រួមទាំងជាអ្នកគ្រប់គ្រងជាន់ខ្ពស់ នៅក្រុមហ៊ុនធានារ៉ាប់រងអាយុជីវិតព្រូដិនសលកម្ពុជាក្នុងឆ្នាំ២០១៧។ នៅក្នុងឆ្នាំ២០១៥ លោកមានតួនាទីជាអ្នកសរសេរកម្មវិធីជាន់ខ្ពស់ នៅគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុអម្រឹត។ ក្រៅពីនេះ លោកធ្លាប់បានដឹកនាំគម្រោងជាច្រើនក្នុងការចូលរួមកម្មវិធី I-ENVEX-2014 នៅប្រទេសម៉ាឡេស៊ី។

លោក កោវិទ្ធ បានបញ្ចប់ថ្នាក់បរិញ្ញាប័ត្រផ្នែកវិទ្យាសាស្រ្តកុំព្យូទ័រ ពីសកលវិទ្យាល័យន័រតុន និងមានជំនាញក្នុងការបង្កើត និងគ្រប់គ្រងប្រព័ន្ធស្នូល របាយការណ៍MIS ឃ្លាំងទិន្នន័យ In-House Application និងជំនួយផ្សេងៗ សម្រាប់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ រួមទាំងក្រុមហ៊ុនធានារ៉ាប់រងផងដែរ។



## លោក សេង កក្កដា
### នាយកសវនកម្មផ្ទៃក្នុងស្តីទី

**លោក សេង កក្កដា** ត្រូវបានតែងតាំងជាប្រធានសវនកម្មផ្ទៃក្នុងនៅ ឥណទានពលរដ្ឋរុងរឿង អិលធីឌី ក្នុងខែឧសភា ឆ្នាំ ២០២០។ ពីមុនលោកធ្លាប់មានបទពិសោធន៍ការងារជាង ៦ ឆ្នាំនៅក្នុងវិស័យហិរញ្ញវត្ថុក្នុងតួនាទីជាច្រើនដូចជា មន្រ្តីឥណទានជាន់ខ្ពស់នៅគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ សាមិក ភីអិលស៊ី ជាសវនករផ្ទៃក្នុងនៅគ្រឹះស្ថាន ឥណទានពលរដ្ឋរុងរឿង និងជាអ្នកវិភាគឥណទាន នៅធនាគារ កាណាឌីយ៉ា។

លោក កក្កដា មានសញ្ញាប័ត្រអនុបណ្ឌិតផ្នែកគ្រប់គ្រងធុរកិច្ច ជំនាញហិរញ្ញវត្ថុ និងធនាគារ ពីសាកលវិទ្យាល័យន័រតុន និងបរិញ្ញាបត្រផ្នែកគ្រប់គ្រងធុរកិច្ច ជំនាញហិរញ្ញវត្ថុ និងធនាគារ ពីសាកលវិទ្យាល័យធនធានមនុស្ស។

# ភាគទុនិក
# និងវិនិយោគិន



## ភាគទុនិក

**លោកឧកញ៉ា ភួ ពុយ**

ជាភាគទុនិកតែម្នាក់គត់ និងជាស្ថាបនិកនៃគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ឥណទានពលរដ្ឋរុងរឿង អិលធីឌី។

## វិនិយោគិន

**លោក ហ្ស៊ូ មីងយី ( Mr. HSU MING-YEE )**ជាពលរដ្ឋលុច ហ្សំប៊ួ ដែលមានលិខិតឆ្លងដែនលេខ H5NJ9N3 ហើយគាត់ជាអភិបាលនៃក្រុមប្រឹក្សាភិបាលរបស់ក្រុមហ៊ុន ឥណទានពលរដ្ឋរុងរឿង អិលធីឌី។





# អង្គការលេខ



ក្រុមប្រឹក្សាភិបាល
គណកម្មការសវនកម្ម និងហានិភ័យ
នាយកប្រតិបត្តិ
នាយកដ្ឋាន ប្រតិបត្តិការ
នាយកដ្ឋាន ហិរញ្ញវត្ថុ និងរដ្ឋបាល
នាយកដ្ឋាន បច្ចេកវិទ្យាព័ត៌មានវិទ្យា
នាយកដ្ឋាន សវនកម្មផ្ទៃក្នុង
ផ្នែកប្រតិបត្តិតាម និងហានិភ័យ
ស្នាក់ការសាខា ០០២
ស្នាក់ការសាខា ០០៣
ស្នាក់ការសាខា ០០៤
ស្នាក់ការសាខា ០០៥
ស្នាក់ការសាខា ០០៦
ស្នាក់ការសាខា ០០៧
ស្នាក់ការសាខា ០០៨




# រចនាសម្ព័ន្ធសាខា

- ប្រធានសាខា
  - អនុប្រធានសាខា
    - មន្ត្រីឥណទាន
    - មន្ត្រីឥណទាន
    - មន្ត្រីឥណទាន
    - មន្ត្រីឥណទាន
    - មន្ត្រីឥណទាន
    - មន្ត្រីឥណទាន
  - គណនេយ្យករសាខា
  - ហេរញ្ញិកសាខា
  - សន្តិសុខ



# អតិថិជនគោលដៅ និងផលិតផល

**អាយភីអា** បានបន្តកែប្រែគោលនយោបាយ និងនីតិវិធីឥណទានរបស់ខ្លួន ហើយបានបង្កើតគោលនយោបាយពាក់ព័ន្ធផ្សេងទៀត ក្នុងការសម្រប ខ្លួនទៅនឹងគោលគំនិតនៃស្តង់ដារនៃការគាំពារអតិថិជន សម្រាប់ប្រតិបត្តិការ និងការអនុវត្តប្រចាំថ្ងៃនៅគ្រប់សាខារបស់អាយភីអា។ ផលិតផលកម្ចីមានស្រាប់ត្រូវបានកែប្រែ ហើយផលិតផលកម្ចីថ្មីត្រូវបានបង្កើតឡើងដើម្បីបំពេញតំរូវការរបស់អតិថិជនជាពិសេសប្រជាជនដែលមានចំណូលទាប និងមធ្យមទាបនៅតំបន់ជនបទនៃប្រទេសកម្ពុជា។ ការធ្វើពិពិធកម្មផលិតផលកម្ចីផ្សេងៗគ្នាមានគោលបំណងដើម្បីទទួលបានអតិថិជនកាន់តែច្រើន។ បញ្ជីរាយនាមផលិតផលកម្ចីថ្មី និងអតិថិជនគោលដៅមានដូចខាងក្រោម៖

| លរ | ពិពណ៌នាពីផលិតផល | អតិថិជនគោលដៅ |
|---|---|---|
| 01 | ឥណទាន កសិកម្ម | អតិថិជនឯកត្តបុគ្គលដែលត្រូវការឥណទានដើម្បីទិញគ្រាប់ពូជ ជី និងសម្ភារៈដាំដុះផ្សេងៗទៀត។ |
| 02 | ឥណទានវិនិយោគ/សម្ភារៈកសិកម្ម | អតិថិជនឯកត្តបុគ្គលដែលត្រូវការឥណទានដើម្បីទិញឧបករណ៍ ម៉ាស៊ីន គ្រឿងចក្រ និងតម្រូវការផ្សេងៗទៀតទាក់ទងនឹងផលិតកម្មកសិកម្ម។ |
| 03 | ឥណទានបង្កើនទ្រព្យ | អតិថិជនឯកត្តបុគ្គលដែលត្រូវការឥណទានដើម្បីទិញដីបន្ថែមសម្រាប់ធ្វើកសិកម្ម និងដើម្បីកែលំអរគេហដ្ឋានឲ្យប្រសើរជាងមុន |
| 04 | ឥណទានអាជីវកម្ម | អាជីវករខ្នាតតូចនិងមធ្យម និងសហគ្រាសផលិតដែលត្រូវការឥណទានដើម្បីទ្រទ្រង់អាជីវកម្មនិងប្រតិបត្តិការ |
| 05 | ឥណទានទូដែក | អាជីវករខ្នាតតូចនិងមធ្យម និងសហគ្រាសផលិតដែលត្រូវការឥណទានដើម្បីទ្រទ្រង់អាជីវកម្មនិងប្រតិបត្តិការ |
| 06 | ឥណទានសម្ភារៈប្រើប្រាស់ក្នុងគេហដ្ឋាន | អតិថិជនជាម្ចាស់ផ្ទះដែលត្រូវការឥណទានដើម្បីទិញសម្ភារៈប្រើប្រាស់ក្នុងគេហដ្ឋាន មានដូចជា ទូទឹកកក ម៉ាស៊ីនបោកខោអាវ ម៉ាស៊ីនត្រជាក់ ទូរទស្សន៍ គ្រឿងសង្ហារឹម ទូរស័ព្ទ ល។ |
| 07 | ឥណទានម៉ូតូ | អតិថិជនឯកត្តបុគ្គល រស់នៅទីក្រុងឬជនបទ ដែលត្រូវការឥណទានដើម្បីទិញម៉ូតូ |
| 08 | ឥណទានប្រើជីង (Bridging) | អតិថិជនឯកត្តបុគ្គល អាជីវករ និងសហគ្រាស ដែលត្រូវការឥណទានសម្រាប់រយៈពេលខ្លី ដោយសារខ្វះទុនក្នុងរយៈពេលខ្លី ឬកំពុងរង់ចាំការសងប្រាក់ត្រលប់ពីអតិថិជនរបស់គាត់ |




# លទ្ធផលការងារឆ្នាំ 2021



# ទិន្នន័យសំខាន់ៗ

| សូចនាករ | ខ្នាត | សវនកម្មឆ្នាំ 2021 | សវនកម្មឆ្នាំ 2020 | សវនកម្មឆ្នាំ 2019 | សវនកម្មឆ្នាំ 2018 |
|---|---|---|---|---|---|
| ចំនួនខេត្តប្រតិបត្តិការ | - | 5 | 8 | 7 | 7 |
| ចំនួនស្រុកប្រតិបត្តិការ | - | 32 | 38 | 35 | 39 |
| ចំនួនឃុំប្រតិបត្តិការ | - | 138 | 164 | 150 | 161 |
| ចំនួនភូមិប្រតិបត្តិការ | - | 494 | 526 | 526 | 605 |
| ចំនួនបុគ្គលិក | - | 72 | 76 | 78 | 91 |
| ចំនួនអតិថិជនសរុប | - | 1949 | 1,987 | 2056 | 2,746 |
| ផលប័ត្រឥណទានសរុប | ដុល្លារ | 6,808,084 | 6,457,611 | 5,827,747 | 6,686,032 |
| ចំណេញសុទ្ធ | ដុល្លារ | 179,343 | 509,474 | 311,876 | 162,354 |
| ទ្រព្យសកម្មសុទ្ធ | ដុល្លារ | 8,028,570 | 7,862,044 | 7,334,626 | 7,265,766 |
| មូលធនសរុប | ដុល្លារ | 7,639,669 | 7,486,936 | 6,977,462 | 6,665,586 |
| អតិថិជនកម្ចីជាស្ត្រី | % | 77.94 | 86.71 | 88.81 | 89.84 |
| អតិថិជនកម្ចីនៅជនបទ | % | 95.43 | 95.22 | 96.64 | 97.82 |
| កម្ចីកសិកម្ម | % | 42.68 | 48.90 | 57 | 82.7 |
| ហានិភ័យឥណទាន | % | 2.05 | 2.29 | 3.67 | 9.27 |
| ឥណទានលុបចេញពីបញ្ជី | % | 1.48 | 1.96 | 5.76 | 4.37 |
| ទិន្នផលផលប័ត្រឥណទាន | % | 18.68 | 21.81 | 19.2 | 20.90 |
| ចំណាយលើមូលនិធិ | % | 0.43 | 0.43 | 0.8 | 2.21 |
| ចំណាយប្រតិបត្តិការ | % | 14.1 | 13.9 | 14.9 | 12.1 |
| ប្រាក់ចំណេញសុទ្ធធៀបនឹងទ្រព្យសកម្ម | % | 1.92 | 6.48 | 4.27 | 1.83 |
| ប្រាក់ចំណេញសុទ្ធធៀបនឹងមូលធន | % | 2.02 | 6.8 | 4.6 | 2.4 |
| បំណុលធៀបនឹងមូលធន | % | 5 | 5 | 5 | 9 |
| **ភាពគ្រប់គ្រាន់ផ្ទាល់លើប្រតិបត្តិការ** | **%** | **130** | **113** | **137.8** | **115.7** |

# លទ្ធផលការងារ

## ផលបត្រឥណទាន









# អនុបាតហិរញ្ញវត្ថុ







ROA and ROE
12.0%
10.0%
8.0%
6.0%
4.0%
2.0%
0.0%
9.9%
5.3%
4.9%
2.8%
2.4%
1.8%
4.6%
4.3%
7.0%
6.7%
2.0%
1.9%
2016
2017
2018
2019
2020
2021
Return on Assets
Return on Equity


Total Loan Amount and Clients Disbursed
14,000,000
12,000,000
10,000,000
8,000,000
6,000,000
4,000,000
2,000,000
0
5,000
4,500
4,000
3,500
3,000
2,500
2,000
1,500
1,000
500
0
11,808,592
9,625,384
6,184,633
5,880,531
6,771,737
6,808,084
4,703
3,379
1,885
1,416
1,475
1,547
2016
2017
2018
2019
2020
2021
Value of Loans Disbursed in Period ($)
# of Loans Disbursed in Period

# បទពិសោធន៍ របស់អតិថិជន

**អ្នកស្រី សុខ ទុំ** នៅចម្ការធុរេនរបស់គាត់ដែលមានដើមធុរេនជាងពីររយដើម។ គាត់ជាអតិថិជនជោគជ័យម្នាក់របស់ អាយភីអា នៅសាខាសំឡូត។ ជាអតិថិជនដ៏ស្មោះត្រង់ម្នាក់របស់យើងតាំងពីឆ្នាំ 2017 ដោយគាត់បានបន្តប្រាក់កម្ចីចំនួន 4 វគ្គមកហើយ គិតត្រឹមចុងឆ្នាំ 2021។ វគ្គទី 4 របស់គាត់ គឺក្នុងគោលបំណងពង្រីកអាជីវកម្ម គឺដាំចំការធុរេន។ ទំហំកម្ចីជាមធ្យមរបស់អ្នកស្រី សុខ ទុំ មានចន្លោះពី ៥000 ទៅ ១0000 ដុល្លារ។

អាជីវកម្មចម្បងរបស់អ្នកស្រី គឺកសិកម្ម គាត់បានដាំដំណាំជាច្រើនប្រភេទ ដូចជា ម្រេច ដំឡូងមី និងសណ្តែក។ ចំណូលពីកសិដ្ឋានម្រេចបានផ្តល់ឲ្យអ្នកស្រី និងក្រុមគ្រួសារនូវប្រភពចំណូលចម្បងរបស់ពួកគេដោយមានដំណាំម្រេច ដល់ ៣00 ដើម។ ប្រភពចំណូលបន្ទាប់បន្សំរបស់អ្នកស្រី គឺដាំដំឡូងមីនៅលើដីចំការទំហំ ៣ ហិកតា។

តាមរយៈប្រាក់កម្ចីរបស់អ្នកស្រីជាមួយ អាយភីអា បានធ្វើអោយគាត់មានលទ្ធភាពចំណាយក្នុងការថែទាំសុខភាពគ្រួសារ មានអាហារល្អ និងអាចចំណាយក្នុងការធ្វើដំណើរជាលក្ខណៈគ្រួសារផងដែរ។ សំខាន់ជាងនេះទៅទៀត អ្នកស្រីអាចបន្តផ្គត់ផ្គង់ការសិក្សារបស់កូនៗ និងសម្ភារៈសិក្សារបស់ពួកគេដែលត្រូវការ។ អ្នកស្រី សុខ ទុំ និងក្រុមគ្រួសារក៏បានបន្ថែមថាគាត់មានលទ្ធភាពទិញបណ្តាញអគ្គិសនីបន្ទាប់ពីពួកគាត់បានប្រើប្រាស់ប្រាក់កម្ចីរបស់អាយភីអាមក។



**អ្នកស្រី សុខ ទុំ**
**ស្រុកសំឡូត ខេត្តបាត់ដំបង**





**អ្នកស្រី ឌួង សួន** កំពុងនៅកសិដ្ឋានចិញ្ចឹមជ្រូករបស់គាត់។ អ្នកស្រីគឺជាអតិថិជនជោគជ័យម្នាក់របស់ អាយភីអា នៅខេត្តបន្ទាយមានជ័យ។ គាត់បានក្លាយជាអតិថិជនរបស់យើងចំនួន 4 វដ្តមកហើយ គិតត្រឹមឆ្នាំ 2021 ដែលបានចាប់ផ្តើមប្រាក់កម្ចីដំបូងនៅក្នុងឆ្នាំ 2018 ក្នុងគោលបំណងទិញដីស្រែមួយ។ ការធ្វើស្រែជាប្រភពចំណូលចំបង និងចិញ្ចឹមសត្វ (ជ្រូក) ជាប្រភពចំណូលបន្ទាប់បន្សំ របស់អ្នកស្រី។ ក្នុងវគ្គទីពីររបស់អ្នកស្រីជាមួយអាយភីអា គឺក្នុងគោលបំណងទិញពូជជ្រូកដើម្បីពង្រីកអាជីវកម្មរបស់គាត់ ក្រៅអំពីការធ្វើស្រែ។ ខណៈដែលក្នុងវគ្គកម្ចីលើកទី៣របស់អ្នកស្រី ឌួង សួន បានប្រើកម្ចីនេះក្នុងគោលបំណងធ្វើស្រែប្រាំង។ រហូតដល់បច្ចុប្បន្ន អ្នកស្រីប្រើចំនួនខ្លះសម្រាប់ធ្វើស្រែប្រាំង និងខ្លះទៀតសម្រាប់កូនគាត់ដែលត្រូវរៀបចំធ្វើអន្តោប្រវេសន៍ទៅធ្វើការនៅក្រៅប្រទេស។

ជាមួយនឹងប្រាក់កម្ចីផ្តល់ដោយ អាយភីអា អ្នកស្រី ឌួង សួនទទួលបានលទ្ធភាពផ្គត់ផ្គង់គ្រួសាររបស់គាត់ ទាំងអាហារគ្រប់គ្រាន់ និងផាសុខភាព រួមទាំងអាចទិញសំលៀកបំពាក់ថ្មីៗសម្រាប់គ្រួសាររបស់គាត់ក៏ដូចជាជួសជុលផ្នែកខ្លះនៃផ្ទះរបស់គាត់ផងដែរ។

**អ្នកស្រី ឌួង សួន**
**ខេត្តបន្ទាយមានជ័យ**



# សវនកម្មផ្ទៃក្នុង និងការត្រួតពិនិត្យ

សវនកម្មផ្ទៃក្នុង ជានាយកដ្ឋានដែលមានវិជ្ជាជីវៈក្នុងការវាយតម្លៃ និងលើកកម្ពស់ប្រសិទ្ធិភាពនៃការគ្រប់គ្រងហានិភ័យ ការត្រួតពិនិត្យ និងដំណើរការគ្រប់គ្រងអភិបាលកិច្ចក្នុងគ្រឹះស្ថាន។ សវនករផ្ទៃក្នុងធ្វើការជាមួយអ្នកគ្រប់ គ្រងដើម្បីត្រួតពិនិត្យប្រព័ន្ធការងារ និងប្រតិបត្តិការរបស់គ្រឹះស្ថាន។ ការត្រួតពិនិត្យឡើងវិញទាំងនេះ សំដៅកំណត់ ថាតើហានិភ័យត្រូវបានគ្រប់គ្រងយ៉ាងដូចម្តេច ដោយរាប់បញ្ចូល ថាតើដំណើរការដែលត្រឹមត្រូវមានហើយឬនៅ ហើយនីតិវិធីដែលបានព្រមព្រៀងគ្នាត្រូវបានអនុវត្តឬអត់។ ការធ្វើសវនកម្មផ្ទៃក្នុង ក៏អាចកំណត់អត្តសញ្ញាណតំបន់ដែលត្រូវបង្កើនប្រសិទ្ធិភាព ឬត្រូវដាក់ឲ្យប្រើប្រាស់នវានុវត្តន៍ថ្មី។ នាយកដ្ឋានសវនកម្មផ្ទៃក្នុងមានបុគ្គលិកចំនួន ៣ នាក់ រួមមាននាយកសវនកម្មផ្ទៃក្នុង ១ នាក់ និងសវនករប្រតិបត្តិការចំនួន ២ នាក់។

ក្នុងឆ្នាំ ២០២១ នាយកដ្ឋានសវនកម្មផ្ទៃក្នុង បានចុះធ្វើសនវកម្មចំនួន ៣ ជុំតាមសាខានីមួយៗ។ ក្នុងជុំទី៣នៃការចុះធ្វើសវនកម្ម យើងបានផ្តោតទៅលើវិសាលភាពមួយចំនួនដែលបានរកឃើញថាមានចំណាត់ថ្នាក់ជាបញ្ហា និង មិនអាចទទួលយកបាន ផ្អែកលើលទ្ធផលសវនកម្មនៃវគ្គមុន។ ជាលទ្ធផលបង្ហាញថា ពិន្ទុ និងចំណាត់ថ្នាក់ហានិភ័យតាមសាខានីមួយៗ គឺហានិភ័យអាចទទួលយកបាន ហានិភ័យកំរិតស្រាល និងហានិភ័យជាបញ្ហា។

ក្នុងឆ្នាំដដែល នាយកដ្ឋានសវនកម្មផ្ទៃក្នុងបានរៀបចំកិច្ចប្រជុំចំនួន ៣ លើកសម្រាប់ការប្រជុំរបស់គណៈកម្មការសវនកម្ម ដើម្បីពិភាក្សាពីរបកគំហើញនានា និងគម្រោងផែនការសម្រាប់ឆ្នាំបន្ទាប់។

ក្នុងនាមជាលេខាធិការមួយរបស់គណកម្មការហានិភ័យ នាយកដ្ឋានសវនកម្មផ្ទៃក្នុង បានផ្ញើជាទៀងទាត់នូវរបាយការណ៍ផែនកំណត់ហានិភ័យជាប្រចាំត្រីមាស និងការចុះបញ្ជីហានិភ័យជាប្រចាំខែទៅកាន់គណកម្មការហានិភ័យ និងក្រុមប្រឹក្សាភិបាល ដើម្បីត្រួតពិនិត្យ និងផ្តល់អនុសាសន៍សម្រាប់ការកែលម្អ ក្នុងករណីដែលចាំបាច់។ នាយកដ្ឋានសវនកម្មផ្ទៃក្នុង បានដាក់ឲ្យប្រើប្រាស់នូវប្រព័ន្ធវាយតម្លៃ និងចំណាត់ថ្នាក់ហានិភ័យដែលឲ្យឈ្មោះថា ”Internal Audit Worksheet and Rating System” សម្រាប់ឥណទានមិនដំណើរការ និងឥណទានលុបចេញពីបញ្ជី។ ប្រព័ន្ធថ្មីនេះបានកំណត់នូវហានិភ័យជាក់លាក់ទៅលើការចំណាត់ការដោះស្រាយ និងតាមដានស្ថានភាពបំណុលតាមអតិថិជននីមួយៗ និងប្រសិទ្ធភាពនៃការគ្រប់គ្រងបំណុលមិនល្អរបស់សាខា។





# បុគ្គលិក និងការកសាងសមត្ថភាព

| សូចនាករ | 2021 | 2020 | 2019 | 2018 |
|---|---|---|---|---|
| **ព័ត៌មានបុគ្គលិក** | | | | |
| *ចំនួនបុគ្គលិកសរុប* | 72 | 76 | 78 | 91 |
| *ចំនួនគណៈគ្រប់គ្រង* | 13 | 14 | 13 | 16 |
| *ភាគរយបុគ្គលិកការិយាល័យ* | 58% | 56% | 56% | 56% |
| *ភាគរយបុគ្គលិកប្រតិបត្តិការ* | 42% | 44% | 44% | 44% |
| **កម្រិតការអប់រំរបស់បុគ្គលិក** | | | | |
| *បរិញ្ញាបត្រជាន់ខ្ពស់* | 6% | 7% | 6% | 7% |
| *បរិញ្ញាបត្រ* | 49% | 50% | 51% | 56% |
| *បរិញ្ញាបត្ររង និងទាបជាងនេះ* | 45% | 43% | 43% | 37% |

# វគ្គបណ្តុះបណ្តាល និងសិក្ខាសាលាក្នុងឆ្នាំ ២០២១

## វគ្គបណ្តុះបណ្តាលខាងក្នុង

1. តម្រង់ទិស និងបណ្តុះបណ្តាលបុគ្គលិកជ្រើសរើសថ្មី
2. គោលការណ៍ និងនិតិវិធីឥណទាន ការសិក្សាវាយតម្លៃឥណទាន និងជំនាញនៃការលក់
3. ការបង្កើត នឹងប្រើប្រាស់ហត្ថលេខា ឌីជីថល
4. ការបណ្តុះបណ្តាលអំពីការប្រើប្រាស់ប្រព័ន្ធផែនការ សកម្មភាពប្រចាំសប្តាហ៍
5. ការបណ្តុះបណ្តាលអំពីការបម្រុងទុកទិន្នន័យ និងនីតិវិធីស្តារឡើងវិញ
6. បណ្តុះបណ្តាលអំពីគោលការណ៍ព័ត៌មានវិទ្យា និងទំនាក់ទំនង
7. ការបណ្តុះបណ្តាលអំពី ឧបសម្ព័ន្ធនៃក្រមសីលធម៌ របស់គ្រឹះស្ថាន

## វគ្គបណ្តុះបណ្តាល និងសិក្ខាសាលាខាងក្រៅ

1. ការសិក្សាឥណទានសម្រាប់សហគ្រាសធុនមធ្យម និងតូច
2. ការពង្រឹងអភិបាលកិច្ច បណ្តុះបណ្តាលដោយ សាជីវកម្ម ហិរញ្ញវត្ថុអន្តរជាតិ
3. ការយល់អំពីច្បាប់ស្តីពីការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម
4. ការអនុវត្តការប្រឆាំងការសម្អាតប្រាក់ និង ហិរញ្ញប្បទាន ភេរវកម្ម
5. ការត្រួតពិនិត្យលើគណនីសង្ស័យជាប្រចាំខែ
6. ការការពារហានិភ័យនៃការកេងបន្លំ និងការស្គាល់អតិថិជន តាមរយៈឌីជីថល
7. បញ្ហាប្រឈមរបស់សវនកម្មផ្ទៃក្នុង និងការអភិវឌ្ឍន៍ជំនាញ នៅកម្ពុជា
8. ច្បាប់ស្តីពីពាណិជ្ជកម្មកម្ពុជា
9. ប្រព័ន្ធប្រកាសពន្ធតាមរយៈE-filling




# ទំនួលខុសត្រូវ
# របស់ ឥណទាន
# ពលរដ្ឋរុងរឿង

# របាយការណ៍
# បង់ពន្ធ

| សូចនាករ | 2021 | 2020 | 2019 | 2018 |
|---|---|---|---|---|
| ពន្ធប៉ាតង់ | 3,681.89 | 3,679.18 | 3,680.98 | $ 4,202.72 |
| ពន្ធលើស្លាកសញ្ញា | 2,292.76 | 426.88 | 485.74 | $240.00 |
| ពន្ធលើមធ្យោបាយដឹកជញ្ជូន | 98.18 | 98.89 | 99.00 | $ 98.89 |
| ពន្ធលើប្រាក់បៀវត្សរ៍ | 22,410.93 | 24,100.02 | 20,667.85 | $ 20,941.05 |
| ប្រាក់រំលស់ពន្ធលើប្រាក់ចំណេញ | 14,186.70 | 13,678.17 | 13,243.41 | $17,325.39 |
| ពន្ធកាត់ទុកលើថ្លៃជួលអចលនទ្រព្យ | 8,334.98 | 9,779.27 | 10,262.38 | 10,860.28 |
| ពន្ធកាត់ទុកលើថ្លៃសេវា ( និវាសនជន ) | 15,621.68 | 11,417.06 | 9,080.97 | $ 8,577.04 |
| ពន្ធកាត់ទុកលើថ្លៃសេវា ( អនិវាសនជន ) | 1,798.85 | 1,768.26 | 1,729.85 | 1,816.94 |
| ពន្ធកាត់ទុកលើការប្រាក់ ( និវាសនជន ) | 4,206.86 | 3,294.12 | 4,211.56 | 4,581.50 |
| ពន្ធកាត់ទុកលើការប្រាក់ ( អនិវាសនជន ) | - | - | 2,275.71 | 16,789.28 |
| ពន្ធលើប្រាក់ចំណេញប្រចាំឆ្នាំ | 52,595.62 | 48,493.21 | 48,219.50 | $ 117.96 |
| ពន្ធប្រថាប់ត្រា | - | - | - | - |
| ពន្ធបន្ថែម | 8,076.93 | - | - | $ 5,619.14 |



# សម្រង់
# របាយការណ៍
# សវនកម្មហិរញ្ញវត្ថុ
# ឆ្នាំ 2021

# របាយការណ៍
# របស់ក្រុមប្រឹក្សាភិបាល

ក្រុមប្រឹក្សាភិបាល មានក្តីសោមនស្សរីករាយ ធ្វើការបង្ហាញនូវរបាយការណ៍របស់ខ្លួន និងរបាយការណ៍ហិរញ្ញវត្ថុរបស់ **ឥណទានពលរដ្ឋរុងរឿង អិលធីឌី** ( ហៅកាត់ថា **"ក្រុមហ៊ុន"** ) ដែលបានធ្វើសវនកម្មរួច សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2021។

## សកម្មភាពចម្បង

សកម្មភាពចម្បងរបស់ក្រុមហ៊ុន គឺការផ្តល់សេវាមីក្រូហិរញ្ញវត្ថុ។ សេវាទាំងនោះ រួមមានការផ្តល់ជូនឥណទានសម្រាប់សហគ្រាសធុនតូច និងគ្រួសារ ដែលមានប្រាក់ចំណូលទាបនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

## លទ្ធផលហិរញ្ញវត្ថុ

លទ្ធផលហិរញ្ញវត្ថុរបស់ក្រុមហ៊ុន មានដូចខាងក្រោម៖

| | 2021<br>ដុល្លារអាមេរិក | 2020<br>ដុល្លារអាមេរិក | 2021<br>ពាន់រៀល<br>( កំណត់សម្គាល់ 5 ) | 2020<br>ពាន់រៀល<br>( កំណត់សម្គាល់ 5 ) |
|---|---|---|---|---|
| ប្រាក់ចំណេញមុនបង់ពន្ធ | 195,218 | 663,902 | 794,146 | 2,706,728 |
| ចំណាយពន្ធលើប្រាក់ចំណេញ | (42,485) | (154,428) | (172,829) | (629,603) |
| ប្រាក់ចំណេញសុទ្ធសម្រាប់ការិយបរិច្ឆេទ | 152,733 | 509,474 | 621,317 | 2,077,125 |

## ដើមទុន

មិនមានការផ្លាស់ប្តូរដើមទុនដែលបានចុះបញ្ជី និងបានបង់របស់ក្រុមហ៊ុនក្នុងកំឡុងការិយបរិច្ឆេទនោះទេ។

## ភាគលាភ

ពុំមានការប្រកាស ឬការបែងបែកភាគលាភទេ ហើយអភិបាលមិនបានស្នើរអោយមានការបែងចែកភាគលាភសម្រាប់ការិយបរិច្ឆេទនោះទេ។

## ទុនបម្រុង និងសំវិធានធន

ពុំមានការប្រែប្រួលជាសារវន្តនៃទុនបម្រុង និងសំវិធានធននៅក្នុងការិយបរិច្ឆេទនេះទេ ក្រៅពីការបង្ហាញនៅក្នុង របាយការណ៍ហិរញ្ញវត្ថុនេះ។

## ឥណទានអាក្រក់ និងជាប់សង្ស័យ

នៅមុនពេលដែលរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុនត្រូវបានរៀបចំឡើង ក្រុមប្រឹក្សាភិបាលបានចាត់វិធានការដែលមានមូលដ្ឋានសមរម្យ ដើម្បីបញ្ជាក់ថាវិធានការទាក់ទងទៅនឹងការលុបបំបាត់ចោលឥណទានអាក្រក់ និងការធ្វើសំវិធានធនលើឥណទានជាប់សង្ស័យ ត្រូវបានធ្វើឡើង ហើយក្រុមប្រឹក្សាភិបាលមានការជឿជាក់ថា រាល់ឥណទាន ដែលបានដឹងថា មិនអាចទារបានត្រូវលុបបំបាត់ចោល ហើយសំវិធានធនគ្រប់គ្រាន់ត្រូវបានកំណត់ឡើងសម្រាប់ឥណទានអាក្រក់ និងជាប់សង្ស័យ។

នាថ្ងៃចេញរបាយការណ៍នេះ ក្រុមប្រឹក្សាភិបាលពុំបានដឹងពីហេតុការណ៍ណាមួយដែលនឹងបណ្តាលឲ្យចំនួននៃការលុបបំបាត់ចោលឥណទានអាក្រក់ ឬ ចំនួននៃការធ្វើសំវិធានធនលើឥណទានជាប់សង្ស័យក្នុងរបាយការណ៍ហិរញ្ញវត្ថុនេះ មានលក្ខណៈមិនគ្រប់គ្រាន់រហូតដល់កម្រិតជាសារវន្តណាមួយនោះទេ។

## ទ្រព្យសកម្ម

នៅមុនពេលដែលរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុនបានរៀបចំឡើង ក្រុមប្រឹក្សាភិបាលបានចាត់វិធានការ ដែលមានមូលដ្ឋានសមរម្យដើម្បីបញ្ជាក់ថា បណ្តាទ្រព្យសកម្មចរន្ត លើកលែងបំណុល ដែលបានកត់ត្រានៅក្នុងបញ្ជីគណនេយ្យរបស់ក្រុមហ៊ុន ហើយដែលសន្និដ្ឋានថា មានតម្លៃមិនអាចប្រមូលមកវិញបាននៅក្នុងប្រតិបត្តិការអាជីវកម្មធម្មតា ត្រូវបានកាត់បន្ថយឲ្យនៅស្មើនឹងតម្លៃដែលគិតថានឹងអាចប្រមូលបានជាក់ស្តែង។

នាថ្ងៃចេញរបាយការណ៍នេះ ក្រុមប្រឹក្សាភិបាលពុំបានដឹងពីហេតុការណ៍ណាមួយដែលនឹងធ្វើឲ្យប៉ះពាល់ដល់ការកំណត់តម្លៃទ្រព្យសកម្មចរន្តនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុនថាមានភាពមិនត្រឹមត្រូវនោះទេ។

## វិធីសាស្រ្តកំណត់តម្លៃ

នាថ្ងៃចេញរបាយការណ៍នេះ ក្រុមប្រឹក្សាភិបាលពុំបានដឹងពីហេតុការណ៍ណាមួយដែលបានកើតឡើង ធ្វើឲ្យប៉ះពាល់ដល់ការអនុវត្តវិធីសាស្រ្តដែលមានកន្លងមក ក្នុងការវាយតម្លៃទ្រព្យសកម្ម និងបំណុលនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុនថាមានភាពមិនត្រឹមត្រូវ ឬមិនសមស្របនោះទេ។

## បំណុលយថាភាព និងបំណុលផ្សេងៗទៀត

នាថ្ងៃចេញរបាយការណ៍នេះ ពុំមានៈ

(ក) ការដាក់បញ្ចាំទ្រព្យសកម្មណាមួយរបស់ក្រុមហ៊ុន ចាប់តាំងពីចុងការិយបរិច្ឆេទមក ក្នុងការធានាចំពោះបំណុលរបស់បុគ្គលណាម្នាក់ឡើយ ឬ

(ខ) បំណុលយថាភាពណាមួយដែលកើតមានឡើងចំពោះក្រុមហ៊ុន ចាប់តាំងពីចុងការិយបរិច្ឆេទមក ក្រៅអំពីប្រតិបត្តិការអាជីវកម្មធម្មតារបស់ក្រុមហ៊ុន។

ក្រុមប្រឹក្សាភិបាលយល់ឃើញថា ពុំមានបំណុលយថាហេតុ ឬបំណុលផ្សេងៗរបស់ក្រុមហ៊ុន ដែលក្រុមហ៊ុនត្រូវបំពេញ ឬអាចនឹងត្រូវបំពេញក្នុងរអំឡុងពេលដប់ពីរខែ បន្ទាប់ពីថ្ងៃបញ្ចប់ការិយបរិច្ឆេទរបាយការណ៍ នឹងមានផលប៉ះពាល់ជាសារវន្តដល់លទ្ធភាពរបស់ក្រុមហ៊ុន ក្នុងការបំពេញកាតព្វកិច្ចរបស់ខ្លួននៅពេលដែលដល់ថ្ងៃកំណត់ឡើយ។

## ប្រតិបត្តិការមិនប្រក្រតី

តាមមតិរបស់ក្រុមប្រឹក្សាភិបាល លទ្ធផលនៃការធ្វើប្រតិបត្តិការរបស់ក្រុមហ៊ុនក្នុងការិយបរិច្ឆេទហិរញ្ញវត្ថុនេះ មិនមានផលប៉ះពាល់ជាសារវន្តដោយសកម្មភាពប្រតិបត្តិការ ឬព្រឹត្តិការណ៍ណាមួយដែលមានលក្ខណៈមិនប្រក្រតីនោះទេ។

ក្រុមប្រឹក្សាភិបាល ក៏មានមតិផងដែរថា នៅក្នុងចន្លោះពេលចាប់ពីថ្ងៃចុងការិយបរិច្ឆេទដល់ថ្ងៃចេញរបាយការណ៍នេះ ពុំមានចំណាត់ថ្នាក់សកម្មភាពប្រតិបត្តិការ ឬព្រឹត្តិការណ៍ណាមួយដែលមានលក្ខណៈជាសារវន្ត និងមិនប្រក្រតីកើតមានឡើង ដែលអាចនាំឲ្យប៉ះពាល់ដល់លទ្ធផលនៃប្រតិបត្តិការរបស់ក្រុមហ៊ុនក្នុងការិយបរិច្ឆេទដែលរបាយការណ៍នេះបានរៀបចំឡើងនោះទេ លើកលែងតែប្រតិបត្តិការសំខាន់ៗដែលបានបង្ហាញនៅកំណត់សម្គាល់26។

## ព្រឹត្តិការណ៍ចាប់តាំងពីកាលបរិច្ឆេទនៃរបាយការណ៍

នាថ្ងៃចេញរបាយការណ៍នេះ លើកលែងតែការបង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ ពុំមានព្រឹត្តិការណ៍ណាមួយដែលកើតឡើងជាសារវន្តក្រោយការិយបរិច្ឆេទរបាយការណ៍ ដែលតម្រូវឲ្យមានការធ្វើនិយ័តភាព និងធ្វើការងបង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុឡើយ។

## ក្រុមប្រឹក្សាភិបាល

សមាជិកក្រុមប្រឹក្សាភិបាល ដែលនៅបម្រើការក្នុងអំឡុងការិយបរិច្ឆេទ និងនាថ្ងៃចេញរបាយការណ៍នេះ រួមមាន៖

- **ឧកញ៉ា ភួ ពុយ** **ប្រធានក្រុមប្រឹក្សាភិបាល**
- **លោក Hsu Ming Yee** **អភិបាលឯករាជ្យ**
- **លោកស្រី ប៉ុក នីរីល័យ** **អភិបាលឯករាជ្យ**
- **លោក ប៊ិច សានី** **អភិបាលឯករាជ្យ (តែងតាំងនៅថ្ងៃទី១ខែមករាឆ្នាំ២០២០)**

## ចំណែកហ៊ុនរបស់ក្រុមប្រឹក្សាភិបាល

ក្រុមប្រឹក្សាភិបាលដែលបានបម្រើការរហូតដល់ចុងការិយបរិច្ឆេទ និងចំណែកហ៊ុនដែលមាននៅក្នុងក្រុមហ៊ុនត្រូវបានបង្ហាញដូចខាងក្រោម៖

| | **2021** | | **2020** | |
|---|---|---|---|---|
| | **% កាន់កាប់** | **ចំនួន ភាគហ៊ុន** | **% កាន់កាប់** | **ចំនួន ភាគហ៊ុន** |
| **ឧកញ៉ា ភួ ពុយ** | | | | |
| 25,955 ភាគហ៊ុនដែលមានតម្លៃចារឹក 119 ដុល្លារអាមេរិកក្នុង 1ភាគហ៊ុន | 100% | 25,955 | 100% | 25,955 |

## អត្ថប្រយោជន៍របស់ក្រុមប្រឹក្សាភិបាល

នៅក្នុងអំឡុងការិយបរិច្ឆេទ និងនៅចុងការិយបរិច្ឆេទនៃរបាយការណ៍ហិរញ្ញវត្ថុនេះ គឺមិនមានកិច្ចព្រមព្រៀងណាមួយដែលក្រុមហ៊ុនជាភាគីម្ខាង ដែលកម្មវត្ថុនៃកិច្ចព្រមព្រៀងនោះអាចផ្តល់លទ្ធភាពដល់ក្រុមប្រឹក្សាភិបាលណាម្នាក់អោយទទួលបាននូវអត្ថប្រយោជន៍តាមមធ្យោបាយផ្សេងៗ ដូចជាការទិញភាគហ៊ុន ឬប័ណ្ណបំណុលរបស់ក្រុមហ៊ុន ឬសាជីវកម្មដទៃ។

ចាប់តាំងពីចុងការិយបរិច្ឆេទហិរញ្ញវត្ថុមុន ពុំមានក្រុមប្រឹក្សាភិបាលណាម្នាក់របស់ក្រុមហ៊ុនបានទទួល ឬមានសិទ្ធិទទួលបាននូវអត្ថប្រយោជន៍ណាមួយ (ក្រៅពីអត្ថប្រយោជន៍ដែលបានរួមបញ្ចូលនៅក្នុងបរិលាភសរុប ទទួលបាន ឬដល់កំណត់ទទួលបានដោយក្រុមប្រឹក្សាភិបាល ដូចបានបង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ) តាមរយៈការចុះកិច្ចសន្យាធ្វើឡើងដោយក្រុមហ៊ុន ឬក៏ជាមួយក្រុមហ៊ុន ដែលក្រុមប្រឹក្សាភិបាលនោះមានផលផ្ទៃកហិរញ្ញវត្ថុច្រើននោះទេ លើកលែងតែការបង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ។

## ការទទួលខុសត្រូវរបស់ក្រុមប្រឹក្សាភិបាលលើរបាយការណ៍ហិរញ្ញវត្ថុ

ក្រុមប្រឹក្សាភិបាលមានភារៈធ្វើការអះអាងបញ្ជាក់ថា របាយការណ៍ហិរញ្ញវត្ថុត្រូវបានរៀបចំឡើងយ៉ាងត្រឹមត្រូវនៃស្ថានភាពហិរញ្ញវត្ថុរបស់ក្រុមហ៊ុន នាថ្ងៃទី 31 ខែធ្នូ ឆ្នាំ2021 ព្រមទាំងលទ្ធផលហិរញ្ញវត្ថុ និងលំហូរទឹកប្រាក់សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់។ នៅក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុនេះក្រុមប្រឹក្សាភិបាលចាំបាច់ត្រូវ៖

- អនុម័តនូវគោលនយោបាយគណនេយ្យដែលសមស្រប ដោយផ្អែកលើការវិនិច្ឆ័យ និងការប៉ាន់ប្រមាណយ៉ាងសមហេតុផល និងប្រុងប្រយ័ត្ន ហើយធ្វើការអនុវត្តប្រកបដោយសង្គតិភាព។
- ត្រួតពិនិត្យប្រព័ន្ធដំណើរការរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន និងរក្សាទុកនូវបញ្ជីគណនេយ្យអោយបានគ្រប់គ្រាន់ និងប្រព័ន្ធគ្រប់គ្រងផ្ទៃក្នុងឲ្យមានប្រសិទ្ធភាព។

- អនុលោមទៅតាមស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា សម្រាប់សហគ្រាសធុនតូច និងមធ្យម ("ស.រ.ទ.ហ.អ.ក សម្រាប់ ស.ត.ម") ឬប្រសិនបើមានការផ្លាស់ប្តូរពីនេះ ដើម្បីបង្ហាញនូវភាពពិត និងត្រឹមត្រូវ គឺត្រូវតែបង្ហាញពន្យល់ និងកំណត់បរិមាណឱ្យបានច្បាស់លាស់នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ។
- វាយតម្លៃនូវលទ្ធភាពរបស់ក្រុមហ៊ុនក្នុងការបន្តនិរន្តរភាពអាជីវកម្ម ទទួលខុសត្រូវលើការលាតត្រដាងព័ត៌មាន ប្រសិនបើពាក់ព័ន្ធនូវបញ្ហាទាំងឡាយដែលទាក់ទងទៅនឹងនិរន្តរភាពអាជីវកម្ម និងប្រើប្រាស់មូលដ្ឋាននិរន្តរភាពនៃគណនេយ្យ លើកលែងតែអ្នកគ្រប់គ្រងមានបំណងចង់ជម្រះបញ្ជីផ្អាកដំណើរការក្រុមហ៊ុន ឬគ្មានជម្រើសសមរម្យដទៃទៀតក្រៅពីធ្វើបែបនេះ និង
- ត្រួតពិនិត្យ និងដឹកនាំក្រុមហ៊ុនឲ្យមានប្រសិទ្ធភាព លើរាល់សេចក្តីសម្រេចដែលមានសារៈសំខាន់ទាំងឡាយ ដែលប៉ះពាល់ដល់សកម្មភាពប្រតិបត្តិការ និងដំណើរការរបស់ក្រុមហ៊ុន ហើយត្រូវប្រាកដថាកិច្ចការនេះត្រូវបានឆ្លុះបញ្ចាំងយ៉ាងត្រឹមត្រូវនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ។

ក្រុមប្រឹក្សាភិបាលបានធានាអះអាងថា ក្រុមប្រឹក្សាភិបាលបានអនុវត្តនូវរាល់តម្រូវការដូចមានរាយការណ៍ខាងលើ ក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន។

## ការអនុម័តលើរបាយការណ៍ហិរញ្ញវត្ថុ

យើងខ្ញុំ សូមធ្វើការអនុម័តលើរបាយការណ៍ហិរញ្ញវត្ថុ ដែលបានបង្ហាញនៅទំព័រទី 10 ដល់ទី 48 ដែលជាមតិរបស់យើងខ្ញុំជាសារវន្ត បានបង្ហាញនូវភាពត្រឹមត្រូវនៃស្ថានភាពហិរញ្ញវត្ថុរបស់ក្រុមហ៊ុននាថ្ងៃទី 31 ខែធ្នូ ឆ្នាំ2021 ព្រមទាំងលទ្ធផលហិរញ្ញវត្ថុ នឹងលំហូរទឹកប្រាក់របស់ក្រុមហ៊ុនសម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ដោយអនុលោមទៅតាមស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជាសម្រាប់សហគ្រាសធុនតូច និងមធ្យម។

*ចុះហត្ថលេខាតំណាងឱ្យក្រុមប្រឹក្សាភិបាល*

**ឧកញ៉ា ភូ ពុយ**

*ប្រធានក្រុមប្រឹក្សាភិបាល*

រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

ថ្ងៃទី29 ខែមេសា ឆ្នាំ2022

# របាយការណ៍
# របស់សវនករឯករាជ្យ

**ជូនចំពោះភាគទុនិករបស់**
**ឥណទានពលរដ្ឋរុងរឿង អិលធីឌី**

### *មតិសវនកម្ម*

យើងខ្ញុំ បានធ្វើសវនកម្មទៅលើរបាយការណ៍ហិរញ្ញវត្ថុរបស់ **ឥណទានពលរដ្ឋរុងរឿង អិលធីឌី** (ហៅកាត់ថា “ក្រុមហ៊ុន”) ដែលរួមមាន របាយការណ៍ស្ថានភាពហិរញ្ញវត្ថុនាថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2021 របាយការណ៍លទ្ធផលលម្អិត របាយការណ៍ស្តីពីបម្រែបម្រួលមូលធន និង របាយការណ៍លំហូរទឹកប្រាក់សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ និងកំណត់សម្គាល់ ដែលរួមមានគោលនយោបាយគណនេយ្យសំខាន់ៗ ព្រមទាំងព័ត៌មានពន្យល់ផ្សេងៗ ដែលបានបង្ហាញនៅទំព័រទី 10 ដល់ទី 48 (ដែលហៅកាត់ថា **របាយការណ៍ហិរញ្ញវត្ថុ**)។

ជាមតិរបស់យើងខ្ញុំ របាយការណ៍ហិរញ្ញវត្ថុជាសារវន្ត បានបង្ហាញនូវភាពត្រឹមត្រូវនៃស្ថានភាពហិរញ្ញវត្ថុរបស់ក្រុមហ៊ុន នាថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2021 ព្រមទាំងលទ្ធផលហិរញ្ញវត្ថុ និងលំហូរទឹកប្រាក់របស់ក្រុមហ៊ុន សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ដោយអនុលោមទៅតាមស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា សម្រាប់សហគ្រាសធុនតូច និងមធ្យម ("ស.រ.ទ.ហ.អ.ក សម្រាប់ ស.ត.ម")។

### *មូលដ្ឋាននៃមតិសវនកម្ម*

យើងខ្ញុំ បានធ្វើសវនកម្មដោយអនុលោមទៅតាមស្តង់ដារសវនកម្មអន្តរជាតិនៃកម្ពុជា។ ការទទួលខុសត្រូវរបស់យើងខ្ញុំ ដែលស្របតាមស្តង់ដារទាំងនោះ ត្រូវបានរៀបរាប់បន្ថែមនៅក្នុងកថាខណ្ឌស្តីពី *ការទទួលខុសត្រូវរបស់សវនករ សម្រាប់ការធ្វើសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុ* ដែលមាននៅក្នុងរបាយការណ៍របស់យើងខ្ញុំ ។ យើងខ្ញុំ មានភាពឯករាជ្យពីក្រុមហ៊ុនដោយស្របទៅតាមតម្រូវការក្រមសីលធម៌វិជ្ជាជីវៈ ដែលពាក់ព័ន្ធនឹងសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុ នៅក្នុងព្រះរាជាណាចក្រកម្ពុជា ហើយយើងខ្ញុំបានបំពេញនូវទំនួលខុសត្រូវលើក្រមសីលធម៌វិជ្ជាជីវៈ ស្របតាមតម្រូវការរបស់ស្តង់ដារទាំងនោះ។ យើងខ្ញុំជឿជាក់ថា ភស្តុតាងសវនកម្មដែលយើងខ្ញុំប្រមូលបានមានលក្ខណៈគ្រប់គ្រាន់ និងសមរម្យសម្រាប់ជាមូលដ្ឋានក្នុងការបញ្ចេញមតិសវនកម្មរបស់យើងខ្ញុំ។

### *ព័ត៌មានផ្សេងៗ*

អ្នកគ្រប់គ្រង មានភារៈទទួលខុសត្រូវលើព័ត៌មានផ្សេងៗ។ ព័ត៌មានផ្សេងៗរួមបញ្ចូលនូវព័ត៌មានដែលមាននៅក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមប្រឹក្សាភិបាលដែលបានបង្ហាញនៅទំព័រទី 1 ដល់ទី 5។ មតិសវនកម្មរបស់យើងខ្ញុំ ទៅលើរបាយការណ៍ហិរញ្ញវត្ថុមិនបានគ្របដណ្តប់លើព័ត៌មានផ្សេងៗឡើយ ហើយយើងខ្ញុំ មិនធ្វើការផ្តល់នូវអំណះអំណាងណាមួយទៅលើព័ត៌មានផ្សេងៗនេះទេ។

ពាក់ព័ន្ធនឹងការធ្វើសវនកម្មរបស់យើងខ្ញុំលើរបាយការណ៍ហិរញ្ញវត្ថុ ការទទួលខុសត្រូវរបស់យើងខ្ញុំគឺត្រូវអានព័ត៌មានផ្សេងៗ ហើយពិចារណាថាតើព័ត៌មានផ្សេងៗនោះ មានភាពមិនស្របគ្នាជាសារវន្តជាមួយរបាយការណ៍ហិរញ្ញវត្ថុ ឬការយល់ដឹងរបស់យើងខ្ញុំនៅក្នុងការធ្វើសវនកម្ម ឬមានបង្ហាញនូវកំហុសឆ្គងជាសារវន្ត។ ប្រសិនបើការអានព័ត៌មានផ្សេងៗ អាចឲ្យយើងខ្ញុំសន្និដ្ឋានថា មានកំហុសឆ្គងជាសារវន្ត កើតឡើងលើព័ត៌មានផ្សេងៗនេះ យើងខ្ញុំត្រូវរាយការណ៍ទៅតាមស្ថានភាពជាក់ស្តែង។ យើងខ្ញុំពុំមានអ្វីដែលត្រូវរាយការណ៍ពាក់ព័ន្ធនឹងព័ត៌មានផ្សេងៗនេះទេ។

### *ការទទួលខុសត្រូវលើរបាយការណ៍ហិរញ្ញវត្ថុរបស់អ្នកគ្រប់គ្រង និងអ្នកទទួលខុសត្រូវលើអភិបាលកិច្ច*

អ្នកគ្រប់គ្រងមានភារៈទទួលខុសត្រូវលើការរៀបចំ និងការបង្ហាញភាពត្រឹមត្រូវនៃរបាយការណ៍ហិរញ្ញវត្ថុ ដោយអនុលោមទៅតាមស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជាសម្រាប់សហគ្រាសធុនតូច និងមធ្យម ហើយនិងទទួលខុសត្រូវលើប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងដែលអ្នកគ្រប់គ្រងកំណត់ថាមានភាពចាំបាច់សម្រាប់ការរៀបចំរបាយការណ៍ហិរញ្ញវត្ថុឲ្យជៀសផុតពីការបង្ហាញខុសជាសារវន្ត ដោយសារតែការក្លែងបន្លំ ឬកំហុសឆ្គង។

នៅក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ អ្នកគ្រប់គ្រងមានភារៈទទួលខុសត្រូវលើការវាយតម្លៃនូវលទ្ធភាពរបស់ក្រុមហ៊ុន ក្នុងការបន្តនិរន្តរភាពអាជីវកម្ម ទទួលខុសត្រូវលើការលាតត្រដាងព័ត៌មាន ប្រសិនបើពាក់ព័ន្ធនូវបញ្ហាទាំងឡាយដែលទាក់ទងទៅនឹងនិរន្តរភាពអាជីវកម្ម និងប្រើប្រាស់មូលដ្ឋាននិរន្តភាពនៃគណនេយ្យ លើកលែងតែអ្នកគ្រប់គ្រងមានបំណងចង់ជម្រះបញ្ជីផ្អាកដំណើរការក្រុមហ៊ុន ឬគ្មានជម្រើសសមរម្យដទៃទៀតក្រៅពីធ្វើបែបនេះ។

អ្នកទទួលខុសត្រូវលើអភិបាលកិច្ច មានភារៈទទួលខុសត្រូវក្នុងការត្រួតពិនិត្យដំណើរការហិរញ្ញវត្ថុរបស់ក្រុមហ៊ុន។

## *ការទទួលខុសត្រូវរបស់សវនករ សម្រាប់ការធ្វើសវនកម្មរបាយការណ៍ហិរញ្ញវត្ថុ*

គោលដៅរបស់យើងខ្ញុំ គឺផ្តល់នូវអំណះអំណាងសមហេតុផលថារបាយការណ៍ហិរញ្ញវត្ថុទាំងមូលមិនមានការបង្ហាញខុសជាសារវន្តដោយសារតែការក្លែងបន្លំ ឬកំហុសឆ្គង និងផ្តល់នូវរបាយការណ៍សវនករដែលរួមបញ្ចូលមតិសវនកម្មរបស់យើងខ្ញុំ។ អំណះអំណាងសមហេតុផល គឺជាអំណះអំណាងមានកម្រិតខ្ពស់មួយ ប៉ុន្តែវាមិនអាចធានាថា គ្រប់ពេលនៃការធ្វើសវនកម្មដោយអនុលោមទៅតាមស្តង់ដារសវនកម្មអន្តរជាតិនៃកម្ពុជា អាចរកឃើញនូវការបង្ហាញខុសជាសារវន្តដែលបានកើតឡើងនោះទេ។ ការបង្ហាញខុសជាសារវន្តអាចកើតឡើងដោយសារ ការក្លែងបន្លំ ឬកំហុសឆ្គង ហើយត្រូវបានចាត់ទុកថាជាសារវន្ត នៅពេលដែលការក្លែងបន្លំ ឬកំហុសឆ្គងតែមួយ ឬក៏រួមបញ្ចូលគ្នា មានផលប៉ះពាល់ដល់ការសម្រេចចិត្តផ្នែកសេដ្ឋកិច្ចរបស់អ្នកប្រើប្រាស់ដោយយោងលើរបាយការណ៍ហិរញ្ញវត្ថុនេះ។

ជាផ្នែកមួយនៃការធ្វើសវនកម្ម ដោយអនុលោមតាមស្តង់ដារសវនកម្មអន្តរជាតិនៃកម្ពុជា យើងខ្ញុំអនុវត្តនូវការវិនិច្ឆ័យដែលប្រកបទៅដោយវិជ្ជាជីវៈ និងរក្សានូវមជ្ឈធាតុនិយម ក្នុងអំឡុងពេលសវនកម្ម។ យើងខ្ញុំក៏៖

- ធ្វើការកំណត់ និងវាយតម្លៃនូវហានិភ័យនៃការបង្ហាញខុសជាសារវន្តលើរបាយការណ៍ហិរញ្ញវត្ថុ ដោយសារតែការក្លែងបន្លំ ឬកំហុសឆ្គង និងទទួលខុសត្រូវលើការរៀបចំ និងការអនុវត្តនីតិវិធីសវនកម្ម ដើម្បីឆ្លើយតបទៅនឹងហានិភ័យទាំងនោះ និងប្រមូលនូវភស្តុតាងដែលមានលក្ខណៈគ្រប់គ្រាន់ និងសមស្របសម្រាប់ជាមូលដ្ឋានក្នុងការបញ្ចេញមតិសវនកម្មរបស់យើងខ្ញុំ។ ហានិភ័យដែលមិនអាចរកឃើញនូវការបង្ហាញខុសជាសារវន្តដែលកើតឡើង ដោយសារតែការក្លែងបន្លំ មានលក្ខណៈខ្ពស់ជាងការបង្ហាញខុសកើតឡើងពីកំហុសឆ្គងដោយសារតែការក្លែងបន្លំ អាចរួមបញ្ចូលទាំងការឃុបឃិតគ្នា ការលួចបន្លំ ការលុបចោលដោយចេតនា ការបកស្រាយមិនពិត ឬមិនអនុវត្តតាមនីតិវិធីគ្រប់គ្រងផ្ទៃក្នុង។
- ទទួលបាននូវការយល់ដឹងអំពីការគ្រប់គ្រងផ្ទៃក្នុង ដែលពាក់ព័ន្ធទៅនឹងសវនកម្ម ក្នុងគោលបំណងដើម្បីរៀបចំនូវនីតិវិធីសវនកម្មដែលសមស្របទៅតាមកាលៈទេសៈ ប៉ុន្តែមិនមែនក្នុងគោលបំណងដើម្បីបញ្ចេញមតិលើប្រសិទ្ធភាពនៃការគ្រប់គ្រងផ្ទៃក្នុងរបស់ក្រុមហ៊ុនឡើយ។
- វាយតម្លៃលើភាពសមស្របនៃគោលនយោបាយគណនេយ្យ ដែលក្រុមហ៊ុនបានប្រើប្រាស់ និងភាពសមហេតុផលនៃការប៉ាន់ស្មានគណនេយ្យសំខាន់ៗ ព្រមទាំងការលាតត្រដាងព័ត៌មានពាក់ព័ន្ធដែលបានធ្វើឡើងដោយអ្នកគ្រប់គ្រង។
- ធ្វើការសន្និដ្ឋានលើភាពសមស្របនៃ ការប្រើប្រាស់មូលដ្ឋាននិរន្តភាពនៃគណនេយ្យរបស់របស់អ្នកគ្រប់គ្រង ហើយដោយផ្អែកលើភស្តុតាងសវនកម្មដែលទទួលបាន ធ្វើការសន្និដ្ឋានថាតើភាពមិនច្បាស់លាស់ជាសារវន្តពាក់ព័ន្ធទៅនឹងព្រឹត្តិការណ៍ ឬលក្ខខណ្ឌដែលអាចធ្វើឲ្យមានមន្ទិលជាសារវន្តលើលទ្ធភាពរបស់ក្រុមហ៊ុនដើម្បីបន្តនិរន្តភាពអាជីវកម្ម។ ប្រសិនបើយើងខ្ញុំធ្វើការសន្និដ្ឋានថាមានអត្ថិភាពនៃភាពមិនប្រាកដប្រជាជាសារវន្ត យើងខ្ញុំចាំបាច់ត្រូវបញ្ចូលនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ ឬប្រសិនបើការលាតត្រដាង ព័ត៌មានមានលក្ខណៈមិនគ្រប់គ្រាន់ យើងខ្ញុំចាំបាច់ត្រូវផ្តល់មតិសវនកម្មដែលមានបញ្ហា។ ការសន្និដ្ឋានរបស់យើងខ្ញុំ គឺផ្អែកតាមភស្តុតាងសវនកម្មដែលប្រមូលបានត្រឹមកាលបរិច្ឆេទនៃរបាយការណ៍សវនកម្មរបស់យើងខ្ញុំ។ យ៉ាងណាក៏ដោយព្រឹត្តិការណ៍ ឬលក្ខខណ្ឌនាពេលអនាគតអាចធ្វើឲ្យក្រុមហ៊ុនបញ្ឈប់និរន្តភាពនៃអាជីវកម្ម។
- វាយតម្លៃលើការបង្ហាញនៃទម្រង់និងខ្លឹមសារនៃរបាយការណ៍ហិរញ្ញវត្ថុទាំងមូល ដែលរួមបញ្ចូលទាំងការលាតត្រដាងព័ត៌មាន និងវាយតម្លៃថាតើរបាយការណ៍ហិរញ្ញវត្ថុបានបង្ហាញពីប្រតិបត្តិការ និងព្រឹត្តិការណ៍ពាក់ព័ន្ធក្នុងអត្ថន័យដែលអាចសម្រេចបាននូវការបង្ហាញរបាយការណ៍ហិរញ្ញវត្ថុដ៏ត្រឹមត្រូវ។

យើងខ្ញុំ ផ្តល់ព័ត៌មានក្នុងចំណោមបញ្ហាផ្សេងៗ ជូនអ្នកទទួលខុសត្រូវលើអភិបាលកិច្ចស្តីពីវិសាលភាព និងពេលវេលាដែលបានគ្រោងទុកសម្រាប់ការធ្វើសវនកម្ម និងការរកឃើញបញ្ហាជាសារវន្តផ្សេងទៀតដែលមានរួមបញ្ចូលទាំងចំណុចខ្វះខាតនៃការគ្រប់គ្រងផ្ទៃក្នុងដែលបានរកឃើញក្នុងអំឡុងពេលធ្វើសវនកម្ម។

តំណាងក្រុមហ៊ុន **ខេភីអឹមជី ខេមបូឌា**

**ហ្វេក ឆាវ**

*Partner*

រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

ថ្ងៃទី29 ខែមេសា ឆ្នាំ2022

# របាយការណ៍ស្ថានភាពហិរញ្ញវត្ថុ

## នាថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2021

| | កំណត់សម្គាល់ | នាថ្ងៃទី៣១ ខែ ធ្នូ 2021 ដុល្លារអាមេរិក | នាថ្ងៃទី៣១ ខែ ធ្នូ 2020 ដុល្លារអាមេរិក | នាថ្ងៃទី៣១ ខែ ធ្នូ 2021 ពាន់រៀល (កំណត់សម្គាល់ 5) | នាថ្ងៃទី៣១ ខែ ធ្នូ 2020 ពាន់រៀល (កំណត់សម្គាល់ 5) |
|---|---|---|---|---|---|
| **ទ្រព្យសកម្ម** | | | | | |
| សាច់ប្រាក់ និងសាច់ប្រាក់សមមូល | 6 | 1,125,713 | 1,345,813 | 4,586,155 | 5,443,814 |
| ប្រាក់បញ្ញើ នៅធនាគារនានា | 7 | 12,500 | 12,500 | 50,925 | 50,563 |
| ប្រាក់តម្កល់តាមច្បាប់ | 8 | 154,432 | 154,432 | 629,156 | 624,677 |
| ឥណទានផ្តល់ដល់អតិថិជន-សុទ្ធ | 9 | 6,563,105 | 6,201,442 | 26,738,090 | 25,084,833 |
| ទ្រព្យសកម្មផ្សេងៗ | 10 | 30,761 | 40,988 | 125,320 | 165,796 |
| ទ្រព្យ និងបរិក្ខារ | 11 | 36,051 | 38,700 | 146,872 | 156,542 |
| ពន្ធពន្យាជាទ្រព្យសកម្ម-សុទ្ធ | 14ក | 106,008 | 68,169 | 431,877 | 275,743 |
| **ទ្រព្យសកម្មសរុប** | | 8,028,570 | 7,862,044 | 32,708,395 | 31,801,968 |
| **បំណុល និងមូលធន** | | | | | |
| **បំណុល** | | | | | |
| ប្រាក់កម្ចី | 12 | 301,875 | 302,000 | 1,229,839 | 1,221,590 |
| បំណុលផ្សេងៗ | 13 | 18,965 | 18,856 | 77,264 | 76,273 |
| បំណុលពន្ធលើប្រាក់ចំណេញប្រចាំឆ្នាំ | 14ខ | 68,061 | 54,252 | 277,280 | 219,449 |
| **បំណុលសរុប** | | 388,901 | 375,108 | 1,584,383 | 1,517,312 |
| **មូលធនភាគទុនិក** | | | | | |
| ដើមទុន | 15 | 3,088,645 | 3,088,645 | 12,468,860 | 12,468,860 |
| ប្រាក់ចំណេញរក្សាទុក | | 4,551,024 | 4,398,291 | 18,403,574 | 17,782,257 |
| ទុនបម្រុងពីការប្តូររូបិយប័ណ្ណ | | - | - | 251,578 | 33,539 |
| **មូលធនសរុប** | | 7,639,669 | 7,486,936 | 31,124,012 | 30,284,656 |
| **បំណុល និងមូលធនសរុប** | | 8,028,570 | 7,334,626 | 32,708,395 | 31,801,968 |

កំណត់សម្គាល់ដែលភ្ជាប់ជូននេះ គឺជាផ្នែកមួយនៃរបាយការណ៍ហិរញ្ញវត្ថុ។

# របាយការណ៍លទ្ធផលលម្អិត

## សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2021

| | កំណត់សម្គាល់ | 2021 ដុល្លារអាមេរិក | 2020 ដុល្លារអាមេរិក | 2021 ពាន់រៀល (កំណត់សម្គាល់ 5) | 2020 ពាន់រៀល (កំណត់សម្គាល់ 5) |
|---|---|---|---|---|---|
| **ចំណូលពីប្រតិបត្តិការ** | | | | | |
| ចំណូលពីការប្រាក់ | 17 | 1,239,109 | 1,237,253 | 5,040,695 | 5,044,280 |
| ចំណាយការប្រាក់ | 18 | (28,382) | (28,235) | (115,458) | (115,114) |
| ចំណូលការប្រាក់សុទ្ធ | | 1,210,727 | 1,209,018 | 4,925,237 | 4,929,166 |
| ចំណូលពីប្រតិបត្តិការផ្សេងៗ | 19 | 184,270 | 170,833 | 749,610 | 696,486 |
| ចំណេញពីប្រតិបត្តិការសុទ្ធ | | 1,394,997 | 1,379,851 | 5,674,847 | 5,625,652 |
| ចំណាយលើបុគ្គលិក | 20 | (541,216) | (532,649) | (2,201,667) | (2,171,610) |
| រំលស់ | 11 | (14,222) | (16,552) | (57,855) | (67,483) |
| ចំណាយប្រតិបត្តិការផ្សេងៗ | 21 | (514,690) | (355,123) | (2,093,759) | (1,447,836) |
| (ការខាតបង់)/ការបង្វិលមកវិញនូវឱនភាពតម្លៃទ្រព្យសកម្មហិរញ្ញវត្ថុ | 9,10 | (129,651) | 188,375 | (527,420) | 768,005 |
| **ប្រាក់ចំណេញមុនដកពន្ធ** | | 195,218 | 663,902 | 794,146 | 2,706,728 |
| ចំណាយពន្ធលើប្រាក់ចំណេញ | 14គ | (42,485) | (154,428) | (172,829) | (629,603) |
| **ប្រាក់ចំណេញសុទ្ធសម្រាប់ការិយបរិច្ឆេទ** | | 152,733 | 509,474 | 621,317 | 2,077,125 |
| ***លទ្ធផល/(ខាត)លម្អិតផ្សេងៗ*** | | | | | |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | | - | - | 218,039 | (225,627) |
| **លទ្ធផលលម្អិតសរុបសម្រាប់ការិយបរិច្ឆេទ** | | 152,733 | 509,474 | 839,356 | 1,851,498 |

កំណត់សម្គាល់ដែលភ្ជាប់ជូននេះ គឺជាផ្នែកមួយនៃរបាយការណ៍ហិរញ្ញវត្ថុ។

# របាយការណ៍ស្តីពីបម្រែបម្រួលមូលធន

## សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2021

| | ដើមទុន | | ប្រាក់ចំណេញរក្សាទុក | | ទុនបម្រុងតាមបទប្បញ្ញត្តិ | | ទុនបម្រុងពីការប្តូររូបិយប័ណ្ណ | | សរុប | |
|---|---|---|---|---|---|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ 5) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ 5) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ 5) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ 5) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ 5) |
| នាថ្ងៃទី 1 ខែ មករា ឆ្នាំ2019 | 3,088,645 | 12,468,860 | 3,872,369 | 15,638,550 | 16,448 | 66,582 | - | 259,166 | 6,977,462 | 28,433,158 |
| **ប្រតិបត្តិការដែលបានទទួលស្គាល់ដោយផ្ទាល់នៅក្នុងមូលធន** | | | | | | | | | | |
| ការផ្ទេរពីទុនបម្រុងតាមបទប្បញ្ញត្តិ ទៅ ប្រាក់ចំណេញរក្សាទុក | - | - | 16,448 | 66,582 | (16,448) | (66,582) | - | - | - | - |
| **ប្រាក់ចំណេញលម្អិតសរុប** | | | | | | | | | | |
| ប្រាក់ចំណេញសុទ្ធសម្រាប់ការិយបរិច្ឆេទ | - | - | 509,474 | 2,077,125 | - | - | - | - | 509,474 | 2,077,125 |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | - | - | - | - | | - | - | (225,627) | - | (225,627) |
| | | | 509,474 | 2,077,125 | | | | (225,627) | 509,474 | 1,851,498 |
| នាថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2020 | 3,088,645 | 12,468,860 | 4,398,291 | 17,782,257 | - | - | - | 33,539 | 7,486,936 | 30,284,656 |
| នាថ្ងៃទី 1 ខែ មករា ឆ្នាំ2021 | 3,088,645 | 12,468,860 | 4,398,291 | 17,782,257 | - | - | - | 33,539 | 7,486,936 | 30,284,656 |
| **ប្រាក់ចំណេញលម្អិតសរុប** | | | | | | | | | | |
| ប្រាក់ចំណេញសុទ្ធសម្រាប់ការិយបរិច្ឆេទ | - | - | 152,733 | 621,317 | - | - | - | - | 152,733 | 621,317 |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | - | - | | - | - | - | - | 218,039 | - | 218,039 |
| | | | 152,733 | 621,317 | | | | 218,039 | 152,733 | 839,356 |
| នាថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2021 | 3,088,645 | 12,468,860 | 4,551,024 | 18,403,574 | - | - | - | 251,578 | 7,639,669 | 31,124,012 |

កំណត់សម្គាល់ដែលភ្ជាប់ជូននេះ គឺជាផ្នែកមួយនៃរបាយការណ៍ហិរញ្ញវត្ថុ។

# របាយការណ៍លំហូរទឹកប្រាក់

## សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2021

| | 2021<br>ដុល្លារអាមេរិក | 2020<br>ដុល្លារអាមេរិក | 2021<br>ពាន់រៀល<br>(កំណត់សម្គាល់ 5) | 2020<br>ពាន់រៀល<br>(កំណត់សម្គាល់ 5) |
|---|---|---|---|---|
| **លំហូរទឹកប្រាក់ពីសកម្មភាពប្រតិបត្តិការ** | | | | |
| ប្រាក់ចំណេញសុទ្ធសម្រាប់ការិយបរិច្ឆេទ | 152,733 | 509,474 | 621,317 | 2,077,125 |
| *និយ័តភាពលើ៖* | | | | |
| ចំណាយពន្ធលើប្រាក់ចំណេញ | 42,485 | 154,428 | 172,829 | 629,603 |
| ចំណូលពីការប្រាក់ | (1,239,109) | (1,237,253) | (5,040,695) | (5,044,280) |
| ចំណាយលើការប្រាក់ | 28,382 | 28,235 | 115,458 | 115,114 |
| (ចំណេញ/ខាតលើការប្តូររូបិយប័ណ្ណបរទេសមិនទាន់ទទួលស្គាល់ | (5,068) | (21,203) | (20,617) | (86,445) |
| រំលស់ | 14,222 | 16,552 | 57,855 | 67,483 |
| ការលុបចោលទ្រព្យ និងបរិក្ខារ | - | 2,446 | - | 9,972 |
| ការខាតបង់/(ការបង្វិលមកវិញ)នៃឱនភាពតម្លៃទ្រព្យសកម្មហិរញ្ញវត្ថុ | 129,651 | (188,375) | 527,420 | (768,005) |
| | (876,704) | (735,696) | (3,566,433) | (2,999,433) |
| *បម្រែបម្រួលនៃ៖* | | | | |
| ឥណទានផ្តល់ដល់អតិថិជន | (448,484) | (835,789) | (1,824,433) | (3,407,512) |
| ទ្រព្យសកម្មផ្សេងៗ | (28,481) | 72,324 | (115,861) | 294,865 |
| បំណុលផ្សេងៗ | 109 | (5,971) | 443 | (24,344) |
| | (1,353,560) | (1,505,132) | (5,506,282) | (6,136,424) |
| ការប្រាក់ដែលបានទទួល | 1,240,055 | 1,251,291 | 5,044,544 | 5,101,513 |
| ការប្រាក់ដែលបានបង់ | (28,507) | (28,235) | (115,966) | (115,114) |
| ពន្ធលើប្រាក់ចំណេញដែលបានបង់ | (66,515) | (60,691) | (270,583) | (247,437) |
| **សាច់ប្រាក់សុទ្ធទទួលបានពីសកម្មភាពប្រតិបត្តិការ** | (208,527) | (342,767) | (848,289) | (1,397,462) |
| **លំហូរទឹកប្រាក់ពីសកម្មភាពវិនិយោគ** | | | | |
| ការទិញទ្រព្យ និងបរិក្ខារ | (11,573) | (31,784) | (47,079) | (129,583) |
| **សាច់ប្រាក់សុទ្ធប្រើប្រាស់ក្នុងសកម្មភាពវិនិយោគ** | (11,573) | (31,784) | (47,079) | (129,583) |
| **ការកើនឡើង(ថយចុះ)សុទ្ធនៃសាច់ប្រាក់ និងសាច់ប្រាក់សមមូល** | (220,100) | (374,551) | (895,368) | (1,527,045) |
| **សាច់ប្រាក់ និងសាច់ប្រាក់ សមមូល នាថ្ងៃទី 1 ខែ មករា** | 1,345,813 | 1,720,364 | 5,443,814 | 7,010,483 |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | - | - | 37,709 | (39,624) |
| **សាច់ប្រាក់ និងសាច់ប្រាក់ សមមូល នាថ្ងៃទី 31 ខែ ធ្នូ (កំណត់សម្គាល់6)** | 1,125,713 | 1,345,813 | 4,586,155 | 5,443,814 |

កំណត់សម្គាល់ដែលភ្ជាប់ជូននេះ គឺជាផ្នែកមួយនៃរបាយការណ៍ហិរញ្ញវត្ថុ។


9:40 10:08 10:34 11:29 11:46 12:05 12:58
EUR /USD
1,95642
2,5386
Open at
Market Price
Lots
1.08
1,62393
1,34528
MARGIN

# ព័ត៌មាន
# ទំនាក់ទំនង



# បណ្តាញសាខា




## ភ្នំពេញ

ការិយាល័យកណ្តាលៈ ផ្ទះលេខ ៧២B, ផ្លូវលេខ ៣១៧, ភូមិ០៦, សង្កាត់បឹងកក់ ០២, ខណ្ឌទួលគោក, រាជធានីភ្នំពេញ។

### ខេត្តតាកែវ

- សាខាតាកែវ

### ខេត្តបន្ទាយមានជ័យ

- សាខាបន្ទាយមានជ័យ

### ខេត្តបាត់ដំបង

- សាខាភ្នំព្រឹក
- សាខាបាត់ដំបង
- សាខាសំពៅលូន
- សាខាសំឡូត

### ខេត្តពោធិ៍សាត់

- សាខាពោធិ៍សាត់

# អាសយដ្ឋានសាខាខេត្ត

## ភ្នំពេញ

### ការិយាល័យកណ្តាល

អាសយដ្ឋាន៖ ផ្ទះលេខ ៧២B, ផ្លូវលេខ ៣១៧, ភូមិ០៦, សង្កាត់បឹងកក់ ០២, ខណ្ឌទួលគោក, រាជធានីភ្នំពេញ។
ទូរសព្ទ៖ ០២៣ ៩៩០ ២៣៧ / ០៧០ ៩៩៩ ៧៣៩
អ៊ីម៉េល៖ info@iprmfi.com
គេហទំព័រ៖ www.iprmfi.com

## ខេត្តតាកែវ

### សាខាតាកែវ

អាសយដ្ឋាន៖ ភូមិខ្សឹង សង្កាត់រកាក្នុង ស្រុកដូនកែវ ខេត្តតាកែវ។
ទូរសព្ទ៖ ០៧០ ៩៩៩ ២៣៣ / ០៧០ ៩៩៩ ២៣៥
អ៊ីម៉េល៖ bm002@iprmfi.com

## ខេត្តពោធិ៍សាត់

### សាខាពោធិ៍សាត់

អាសយដ្ឋាន៖ ភូមិខ្នាចរមាស ឃុំបឹងខ្នារ ស្រុកបាកាន ខេត្តពោធិ៍សាត់។
ទូរសព្ទ៖ ០៧០ ៩៩៩ ៤៩៥ / ០៧០ ៩៩៩ ៤៩១
អ៊ីម៉េល៖ bm005@iprmfi.com

## ខេត្តបាត់ដំបង

### សាខាភ្នំព្រឹក

អាសយដ្ឋាន៖ ភូមិភ្នំតូច ឃុំពេជ្រចិន្តា ស្រុកភ្នំព្រឹក ខេត្តបាត់ដំបង។
ទូរសព្ទ៖ ០៧០ ៩៩៩ ៣២៣ / ០៧០ ៩៩៩ ៣២៥
អ៊ីម៉េល៖bm003@iprmfi.com

### សាខាបាត់ដំបង

អាសយដ្ឋាន៖ ភូមិអញ្ចាញ សង្កាត់អូរចារ ក្រុងបាត់ដំបង ខេត្តបាត់ដំបង។
ទូរសព្ទ៖ ០៧០ ៩៩៩ ៦៩៤ / ០៧០ ៩៩៩ ៦៩២
អ៊ីម៉េល៖ bm007@iprmfi.com

### សាខាសំពៅលូន

អាសយដ្ឋាន៖ ផ្ទះលេខ ៥៧B ភូមិត្រពាំងព្រលិត ឃុំសន្តិភាព ស្រុកសំពៅលូន ខេត្តបាត់ដំបង។
ទូរសព្ទ៖ ០៧០ ៩៩៩ ៣២៦ / ០៧០ ៩៩៩ ៣៤៧
អ៊ីម៉េល៖ bm007@iprmfi.com

### សាខាសំឡូត

អាសយដ្ឋាន៖ ភូមិតាសាញខាងជើង ឃុំតាសាញ ស្រុកសំឡូត ខេត្តបាត់ដំបង។
ទូរសព្ទ៖ ០៧០ ៩៩៩ ៧៣៤ / ០៧០ ៩៩៩ ៧២៦
អ៊ីម៉េល៖ bm010@iprmfi.com

## ខេត្តបន្ទាយមានជ័យ

### សាខាបន្ទាយមានជ័យ

អាសយដ្ឋាន៖ ភូមិអូរស្ងួត ឃុំបន្ទាយនាង ស្រុកមង្គលបូរី ខេត្តបន្ទាយមានជ័យ។
ទូរសព្ទ៖ ០៧០ ៩៩៩ ៤៧៨ / ០៧០ ៩៩៩ ៧៤៩
អ៊ីម៉េល៖ bm004@iprmfi.com




ផ្ទះលេខ ៧២B, ផ្លូវលេខ ៣១៧, ភូមិ០៦,
សង្កាត់បឹងកក់ ០២, ខណ្ឌទួលគោក, រាជធានីភ្នំពេញ
Tel: 023 990 237 / 070 999 739 / E-mail: info@iprmfi.com / Website: www.iprmfi.com